**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royal de droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# សិទ្ធិរបស់ជនល្មើស ក្នុងរឿងក្ដីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០

តាក់តែងឡើងដោយ

និសិត្សឈ្មោះ **ក.អាន ស៊ីវលី**

**ក.ខួន និរ័ត្ន**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១
## ភាគីចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌ

**១.១ ភាគីជនល្មើស** ........................................ ៤
១.១.១ ជនល្មើស ........................................ ៤
ក. ជនសង្ស័យ ........................................ ៤
ខ. ជនត្រូវចោទ ........................................ ៤
គ. ជនជាប់ចោទ ........................................ ៥
ឃ. ពិរុទ្ធជន ........................................ ៥
ង. ទណ្ឌិត ........................................ ៥
១.១.២ ចារី ........................................ ៥
១.១.៣ សហចារី ........................................ ៦
១.១.៤ អ្នកផ្តើមគំនិត ........................................ ៦
១.១.៥ អ្នកសមគំនិត ........................................ ៧
**១.២ ភាគីរដ្ឋ** ........................................ ៨
១.២.១ នគរបាលយុត្តិធម៌ ........................................ ៨
១.២.២ ព្រះរាជអាជ្ញា ........................................ ៨
១.២.៣ ចៅក្រមស៊ើបសួរ ........................................ ៩
១.២.៤ ចៅក្រមជំនុំជម្រះ ........................................ ៩
**១.៣ ភាគីពាក់ព័ន្ធដ៏ទៃទៀត** ........................................ ៩
១.៣.១ មេធាវី ........................................ ៩
១.៣.២ សាក្សី ........................................ ១០

## ជំពូកទី២
## សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ

**២.១ សិទ្ធិទទួលបានជំនួយផ្នែកច្បាប់** ........................................ ១២

២.១.១ សិទ្ធិស្នើសុំមេធាវី......១៣
២.១.២ សិទ្ធិទទួលបានគ្រូពេទ្យ......១៤
២.១.៣ សិទ្ធិទទួលបានព័ត៌មាន......១៦
**២.២ សិទ្ធិទទួលបានការស៊ើបអង្កេតដោយត្រឹមត្រូវ និងយុត្តិធម៌......១៧**
២.២.១ សិទ្ធិទទួលដឹងពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់......១៧
២.២.២ សិទ្ធិទទួលបានការសួរចម្លើយតាមច្បាប់គ្មានអំពើហិង្សា ទណ្ឌកម្ម និងអំពើអមនុស្សធម៌......១៩
២.២.៣ សិទ្ធិទទួលដឹងពីភស្តុតាង សាក្សី......២០
២.២.៤ សិទ្ធិទទួលបានការនៅក្រៅឃុំ......២១
២.២.៥ លក្ខខណ្ឌរបស់ជនជាប់ឃុំ......២២
**២.៣ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌......២៥**
២.៣.១ សិទ្ធិទទួលបាននូវការកាត់សេចក្តីជាសាធារណៈ......២៧
២.៣.២ ការសន្មត់ជាមុនថាគ្មានទោស......២៨
២.៣.៣ សិទ្ធិទទួលបាននូវការជំនុំជម្រះដោយគ្មានពន្យាពេល......២៩
២.៣.៤ សិទ្ធិត្រូវមានការសួរចម្លើយ និងត្រូវពិនិត្យសាក្សី......៣១

## ជំពូកទី៣

## ការបន្ធូរបន្ថយទោស និងការលើកលែងទោស

**៣.១ លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស......៣២**
**៣.២ លក្ខខណ្ឌនៃការលើកលែងទោស......៣៣**
**៣.៣ អានុភាពនៃការលើកលែងទោស......៣៦**
**សេចក្តីសន្និដ្ឋាន......៣៧**
**អនុសាសន៍......៣៩**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# **អារម្ភកថា**

ក្រោយពីបានសិក្សាអស់រយៈពេល ០៤ ឆ្នាំនូវផ្នែកនីតិសាស្ត្រហើយមានឈ្មោះ នៅក្នុងបញ្ជីនៃក្រុមនិស្សិតសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "**សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ**" មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

ការស្វែងយល់អំពីសិទ្ធិរបស់ជនជាប់ចោទ ជាកត្តាចូលរួមចំណែកក្នុងការគោរពសិទ្ធិមនុស្ស និងចូលរួមកែលម្អដល់ដំណើរការនៃស្ថាប័នតុលាការឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាពខ្ពស់។ គ្រប់ភាគីទាំងអស់មិនថាជនល្មើស ឬជនរងគ្រោះ ឬជនពាក់ព័ន្ធដ៏ទៃ គួរតែឃ្វីស្វែងយល់អំពីសិទ្ធិទាំងនោះ។ ជាពិសេសសិស្សនិស្សិត ព្រោះវាជា យានមួយសម្រាប់ចម្លងយើងដល់គោលដៅ។

ហេតុដូចនេះហើយបានជាយើងខ្ញុំ សម្រេចជ្រើសរើសយកប្រធានបទនេះមកធ្វើការចងក្រងជាសារណានេះឡើងដើម្បីសិក្សាបន្ថែម និងទុកជាឯកសារជំនួយដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត អ្នកសិក្សាជំនាន់ក្រោយៗ រួមទាំងទុកជាអនុស្សាវរីយ៍ក្រោយការបញ្ចប់ការសិក្សា។

ការសិក្សា ចងក្រងសារណាមួយនេះឡើង ពិតណាស់ថានឹងមានចំណុចខ្វះខាតនូវរាល់ពាក្យពេចន៍ខ្លឹមសារ ក៏ដូចជាកំហុសអក្ខរាវិរុទ្ធជាក់ជាពុំខាន។ យើងខ្ញុំជានិស្សិតដែលធ្វើការចងក្រងនេះនឹងរងចាំទទួល និងស្វាគមន៍ចំពោះមតិយោបល់ ការរិះគន់ សម្រាប់ការកែលម្អបន្ថែមដើម្បីបំពេញបន្ថែមរាល់ចំណុចខ្វះខាតពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានដោយក្តីគោរព។ ជាមួយគ្នានេះផងដែរ យើងខ្ញុំសូមការអភ័យទោសចំពោះកំហុសឆ្គងដោយអចេតនាដែលកើតមានឡើងក្នុងកិច្ចការមួយនេះ។

ជាចុងក្រោយសូម លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមគោរពអរគុណ!

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតឆ្នាំទី៤ ជំនាន់ទី២០ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៦-២០២០។ យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកឪពុក ម៉ិច គឹមខួន** និង**អ្នកម្តាយ ហុង ឆេងគាង** និង**លោកឪពុក ខួន សារិន** និង **អ្នក ម្តាយ ស៊ឹម ហ៊ីច** ជាទីគោរពស្រលាញ់នៃកូនដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តា ករុណា ចំពោះរូបកូនតាំងពីតូចរហូតដល់ធំពេញវ័យដែលរូបលោកទាំងពីរបានលះបង់គ្រប់យ៉ាងនូវកម្លាំងកាយចិត្ត ថវិកា អប់រំ ទូន្មានប្រៀបប្រដៅ ជំរុញលើកទឹកចិត្តដល់កូនក្នុងការសិក្សារៀនសូត្រ តាំងតែរូបកូននៅតូចរហូតដល់រូបកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ។

ទន្ទឹមនេះផងដែរយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ធ្លា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំបង្ហាត់បង្ហាញ និងផ្តល់ជាចំណេះដឹងដល់យើងខ្ញុំ ទើបយើងខ្ញុំអាចសរសេរសារណាប្រកបដោយជោគជ័យ។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ជាសាស្ត្រាចារ្យណែនាំ ដែលបានជួយផ្តល់មតិយោបល់ កែតម្រូវ និងជំរុញឱ្យកិច្ចការសរសេរសារណាទទួលបានជោគជ័យ។

ចុងបញ្ចប់នេះ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិ ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យជូនដល់អ្នកមានគុណទាំងទ្វេ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ជួបតែនឹងសេចក្តីសុខ សេចក្តីចម្រើននៅក្នុងជីវិតរៀងទៅ ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ដំណើរការប្រកបដោយឯករាជ្យ និងប្រសិទ្ធភាពនៃស្ថាប័នតុលាការ គឺជាចំណុចសំខាន់ក្នុងកិច្ចការពារ និងការគោរពសិទ្ធិមនុស្ស។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងមានករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។[១]

មនុស្សគ្រប់រូបទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ។[២] ក្នុងន័យនេះរាប់បញ្ចូលទាំងជនសង្ស័យ ជនជាប់ចោទក្នុងរឿងក្តីព្រហ្មទណ្ឌ។ ប្រសិនបើយើងត្រូវជាប់ចោទពីបទព្រហ្មទណ្ឌ យើងត្រូវចាត់ទុកថាជាមនុស្សគ្មានទោសរហូតទាល់តែមានសាលក្រម ពីតុលាការប្រកបដោយភាពយុត្តិធម៌ថាយើងពិតជាមានកំហុស។ យើងមានសិទ្ធិការពារខ្លួន គ្មាននរណាម្នាក់អាចចោទប្រកាន់ទោសយើង ឬដាក់ទោសយើងចំពោះអ្វីដែលយើងមិនបានប្រព្រឹត្តនោះទេ។

គោលបំណង នៃការពារសិទ្ធិរបស់ជនជាប់ចោទ គឺសំដៅទៅលើការធានាការពារសិទ្ធិទាំងឡើយដែលជនជាប់ចោទទទួលបានក្នុងអំឡុងពេលឃាត់ខ្លួន។ គោលការណ៍ជាមូលដ្ឋាននៃសិទ្ធិរួមមានដូចជា៖

- ជនគ្រប់រូប មានភាពស្មើៗគ្នានៅចំពោះមុខតុលាការ និងសាលាជំនុំជម្រះក្តី
- ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសវនាការជាសាធារណៈពី សាលាជំនុំជម្រះដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង
- ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ជននោះត្រូវបានរកឃើញ
- ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លង ជាមួយមេធាវី

[១] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[២] មាត្រា ១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

- ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួសហេតុ

## ២. ចំណោទបញ្ហា

សៀវភៅសារណាមួយនេះ ដែលមានចំណងជើងថា **សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ** គឺក្រុមយើងខ្ញុំបានកំណត់នៅ សំណួរស្រាវជ្រាវមួយចំនួនដូចជា

- តើមានភាគីណាខ្លះ ដែលបានចូលរួមដំណើរការរឿងក្តីព្រហ្មទណ្ឌ?
- ប្រសិនបើបុគ្គលធម្មតាម្នាក់ខ្លាចជា ជនល្មើស តើគាត់នឹងត្រូវទទួលបានសិទ្ធិអ្វីខ្លះ?
- ក្រោយពេលក្លាយជាទណ្ឌិតហើយ តើមានលក្ខខណ្ឌណាខ្លះដែលធ្វើឱ្យទណ្ឌិតអាចនឹងទទួលបានការបន្ធូរបន្ថយទោស ឬលើកលែងទោស?

## ៣. គោលបំណងក្នុងការសរសេរសារណា

គោលបំណងនៃសារណាមួយនេះ គឺដើម្បីសិក្សាស្វែងយល់សិទ្ធិរបស់ជនល្មើសចាប់តាំងពីដំណាក់កាលដំបូងនៃការឃាត់ខ្លួន រហូតដល់ដំណាក់កាលនៃការបញ្ចប់ការជំនុះជម្រះ។ សារណា មួយនេះក៏នឹងឆ្លុះបញ្ចាំងអំពីច្បាប់ជាតិ ក៏ដូចជាលិខិតូបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្សសំខាន់ៗ មួយចំនួនដែលបានកំណត់អំពីសិទ្ធិរបស់ជនល្មើសក្នុងរឿក្តីព្រហ្មទណ្ឌ ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនៃសារណានេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារគោល គឺរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១ និងឯកសាររួមផ្សំដែលពាក់ព័ន្ធហើយដែលបានលើកឡើងនៅក្នុងឯកសារយោងស្រាប់។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធិសាស្ត្រស្រាវជ្រាវនៃសារណានេះ ត្រូវបានរៀបចំឡើងប្រើប្រាស់នូវវិធីសាស្ត្របែបពិពណ៌នា។ការសិក្សា និងស្រាវជ្រាវដោយធ្វើការប្រមូល ចងក្រងនូវរាល់បណ្តាឯកសារគតិយុត្ត លិខិតូបករណ៍គតិយុត្តអន្តរជាតិដែលពាក់ព័ន្ធនឹងប្រធានបទខាងលើ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាភាពងាយស្រួលក្នុងការស្វែងយល់ពីខ្លឹមសារ និងជាសោភ័ណ្ឌភាព យើងខ្ញុំបានរៀបចំរចនាសម្ព័ន្ធនៃសារណានេះជា **៣ជំពូក** ដូចខាងក្រោម ៖

**ជំពូកទី១ ភាគីចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌ** ៖ គឺជាការប្រមូលនូវរាល់ភាគីនានាដែលបានទាក់ទិនក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងអស់រួមមានភាគីជាជនល្មើស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ភាគីជារដ្ឋ និងភាគីពាក់ព័ន្ធដ៏ទៃទៀតដូចជាសាក្សី និងមេធាវីជាអាទិ៍។

**ជំពូកទី២ សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ៖** ជំពូកនេះ គឺនឹងសេសេរពីសិទ្ធទាំងឡាយណាដែលភាគីជាជនល្មើសនឹងត្រូវទទួលបានចាត់តាំងពីដំណាក់កាលដំបូងនៃការឃាត់ខ្លួន រហូតដំណាក់កាលបញ្ចប់នៃនីតិវិធីព្រហ្មទណ្ឌដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តទាំងជាតិ និងអន្តរជាតិ។

**ជំពូកទី៣ ការបន្ធូរបន្ថយទោស និងការលើកលែងទោស ៖** នៅក្នុងជំពូកនេះ គឺបានសេសេរពីលក្ខខណ្ឌនៃការបន្ធូរបន្ថយទោល និងលើកលែងទោស រួមជាមួយអានុភាពនៃការបន្ធូរបន្ថយទោល និងលើកលែងទោស។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៖** គឺការស្វែងរកចំណុចវិជ្ជមាន និងចំណុចខ្វះខាតដែលអាចកើតមានឡើង និងការផ្តល់ជាយោបល់ដើម្បីចូលរួមចម៌ណែកកាត់បន្ថយនូវកង្វះខាតទាំងឡាយដែលបានកើតមានឡើង។

## គំនូសបំព្រួញនៃរចនាសម្ព័ន្ធ



# ជំពូកទី១

# ភាគីចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌ

# ជំពូកទី១

# ភាគីចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌ

ការស្វែងយល់អំពីសមាសភាពភាគី ដែលចូលរួមក្នុងរឿងក្តីព្រហ្មទណ្ឌ ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការសិក្សាឱ្យកាន់តែស៊ីជម្រៅ និងមានភាពរលូន។

ជាទូទៅ ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌមានដូចជាភាគីរដ្ឋ ភាគីជនល្មើស និងមានភាគីពាក់ព័ន្ធដ៏ទៃទៀតរួមមានមេធាវី សាក្សីជាអាទិ៍។

## ១.១ ភាគីជនល្មើស

### ១.១.១ ជនល្មើស

**ជនល្មើស** គឺអាចជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តនូវអំពើល្មើសច្បាប់ណាមួយ ដែលខ្លួនត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនបានប្រព្រឹត្តតាមការកំណត់របស់ច្បាប់។ ពាក្យជនល្មើសនេះទៀតសោត ត្រូវបានប្រជាពលរដ្ឋទូទៅប្រើសម្តៅដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

ផ្អែកតាមបញ្ញត្តិ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការប្រើប្រាស់វាក្យស័ព្ទចំពោះជនដែលបានប្រព្រឹត្តបទល្មើសនេះ(ជនល្មើស) គឺប្រែប្រួលទៅតាមដំណាក់កាលនីមួយៗនៃដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌដែលក្នុងនោះរួមមានជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន និង ទណ្ឌិត។

### ក. ជនសង្ស័យ

**ជនសង្ស័យ** ជាពាក្យបច្ចេកទេសមួយដែលបានប្រើប្រាស់ និងមានចែងក្នុងមាត្រា១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ វាក្យស័ព្ទនេះត្រូវបានយកមកប្រើនៅក្នុងដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលព្រះរាជអាជ្ញាបើកកិច្ចស៊ើបអង្កេត ទាំងការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតករណីជាក់ស្តែងដើម្បីសម្គាល់ជនទាំងឡាយដែលគេសង្ស័យថាបានប្រព្រឹត្តនូវរាល់បទល្មើសព្រហ្មទណ្ឌ។

### ខ. ជនត្រូវចោទ

**ជនត្រូវចោទ** ជាពាក្យបច្ចេកទេសមួយដែលបានប្រើប្រាស់និងមានចែងក្នុងមាត្រាមួយចំនួន នៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមមានមាត្រា ១៣៣ ១៤៩ ២១៥ និងមាត្រា ២១៧។

**ជនត្រូវចោទ** ជាពាក្យដែលប្រើសម្រាប់សម្គាល់នៅក្នុងដំណាក់កាលរបស់អយ្យការ ពោលគឺនៅពេលព្រះរាជអាជ្ញា បានបើកកិច្ចស៊ើបអង្កេតរួចរាល់ ហើយបានសម្រេចចិត្ត ធ្វើការចោទប្រកាន់ទៅលើជនសង្ស័យ ពេលនោះហើយដែលមានការផ្លាស់ប្តូរពាក្យប្រើប្រាស់ពីជនសង្ស័យមកជាជនត្រូវចោទ។ ពាក្យនេះត្រូវបានប្រើប្រាស់រហូតដល់កិច្ចរបស់ចៅក្រមស៊ើបសួរមុនពេលបញ្ជូនទៅជំនុំជម្រះ។

**គ.ជនជាប់ចោទ**

**ជនជាប់ចោទ** ជាពាក្យបច្ចេកទេសមួយដែលបានប្រើប្រាស់និងមានចែងក្នុងមាត្រាមួយចំនួន រួមមាន មាត្រា ២៩១ ៣៤៩ និងមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ជនជាប់ចោទ** ជាពាក្យដែលប្រើសម្រាប់សម្គាល់ជនល្មើសនៅ ក្នុងដំណាក់កាលបញ្ជូនទៅជំនុំជម្រះចំពោះមុខតុលាការ[៣] ពោលពាក្យនេះចាប់ផ្តើមប្រើនៅពេលដែលមានការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះដោយព្រះរាជអាជ្ញា តាមកំណត់ហេតុបង្ហាញខ្លួនភ្លាម តាមដីកាកោះបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬនៅពេលដែលចៅក្រមស៊ើបសួរសម្រេចបញ្ចប់ការស៊ើបសួរដោយបញ្ជូនទៅជំនុំជម្រះ។

**ឃ. ពិរុទ្ធជន**

**ពិរុទ្ធជន** ជាពាក្យបច្ចេកទេសមួយដែលបានប្រើប្រាស់និងមានចែងក្នុងមាត្រាមួយចំនួន រួមមាន មាត្រា៣៥៣ ៣៦៥ ៣៧៦ ៣៨៧ ៤០៧ ៤០៩ និងមាត្រា៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ វាក្យស័ព្ទនេះត្រូវបានយកមកប្រើក្រោយពីមានសេចក្តីសម្រេចរបស់តុលាការដើម្បីផ្តន្ទាទោសជនជាប់ចោទទាំងនោះ។[៤] បានន័យថា នៅពេលដែលតុលាការចេញសេចក្តីសម្រេចផ្តន្ទាទោស ជនជាប់ចោទហើយ ជននោះត្រូវបានគេហៅថាជាពិរុទ្ធជនវិញលែងជាជនជាប់ចោទបន្តទៀតហើយ។

ក្នុងករណីដែលពិរុទ្ធជនប្តឹងទាល់ ឬប្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចរបស់តុលាការ ដែលផ្តន្ទាទោសខ្លួន នោះគេនឹងហៅពិរុទ្ធជនរូបនោះថាជាជនជាប់ចោទវិញ។

**ង. ទណ្ឌិត**

**ទណ្ឌិត** ជាពាក្យបច្ចេកទេសមួយដែលបានប្រើប្រាស់និងមានចែងក្នុងមាត្រាមួយចំនួន រួមមាន មាត្រា ៤៤៥ ៤៤៦ ៤៥១ និងមាត្រាបន្តបន្ទាប់ទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

វាក្យស័ព្ទនេះត្រូវបានយកមក ប្រើក្រោយពេលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ ហើយក៏សម្គាល់ថាជននោះត្រូវបានតុលាការសម្រេចផ្តន្ទាទោស។ ពាក្យទណ្ឌិត ត្រូវបានប្រើរហូតទោះបីជាមានការប្តឹងសើរើក៏ដោយ។

**១.១.២ ចារី**

**ចារី** ជនដែលត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក

[៣] មាត្រា២៩១ កថាខណ្ឌទី២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៤] មាត្រា៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចំពោះបទមជ្ឈិម។[៥] **ចារី** នៃបទល្មើស គឺជាជនដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬ ជនដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬអាចហៅម្យ៉ាងទៀតថាជនដៃដល់ផងដែល។ ចារី ត្រូវបានច្បាប់ចាត់ទុកថាជាអ្នកដែលមានទួនាទីសំខាន់នៅក្នុងបទល្មើស។ ប្រសិនបើគ្មានអំពីល្មើសរបស់ចារីទេ នោះក៏គ្មានបទល្មើសកើតឡើងដែរ។

ឧទាហរណ៍៖ បុគ្គល ក បានយកកាំបិតទៅចាក់សម្លាប់បុគ្គល ង ។ ដូចនេះបុគ្គល ក ត្រូវបានចាត់ទុកជាចារីដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសពីបទល្មើសមនុស្សឃាត។

### ១.១.៣ សហចារី

***សហចារី*** ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀង ប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។[៦] សហចារីនៃបទល្មើស គឺជាជនដែលបានចូលរួម និងមានសកម្មភាពប្រព្រឹត្តអំពើល្មើសដោយផ្ទាល់ជាមួយចារី ហើយស្ថិតក្នុងកាលៈទេសៈ និងទីកន្លែងតែមួយជាមួយចារី ។

ឧទាហរណ៍៖ បុគ្គល ក បានយកកាំបិតទៅចាក់សម្លាប់បុគ្គល ង ដោយក្នុងនោះមានបុគ្គល ខ និង គ បានចូលរួមសកម្មភាពដោយបានចាប់ដៃ ចាប់ជើង និងវាយដំលើបុគ្គល ង។ ដូចនេះបុគ្គល ក ត្រូវបានចាត់ទុកជាចារី និងបុគ្គល ខ គ ចាត់ទុកជាសហចារី ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺបទល្មើសមនុស្សឃាត។

### ១.១.៤ អ្នកផ្តើមគំនិត

**អ្នកផ្តើមគំនិត** ជាជនត្រូវចាត់ទុកថាជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល៖

- ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា ។
- បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។[៧]

ក្នុងន័យនព អ្នកផ្តើមគំនិត ឬចារីបញ្ញា គឺជាអ្នកដែលចាប់ផ្តើមគំនិត ការគិតទុច្ចរិតណែនាំ បញ្ជា ញុះញង់ និងគំរាមកំហែងឬក៏ជាការលួងលោមអោយប្រព្រឹត្តបទល្មើសជាដើម។ អំពើទាំងនេះ អាចត្រូវបានធ្វើឡើងដោយផ្ទាល់ក្តី ឬតាមសម្ភារៈអេឡិចត្រូនិកក្តី ក៏ត្រូវចាត់ទុកជាអ្នកផ្តើមគំនិត ហើយនឹងត្រូវទទួលទោសដូចគ្នា

---

[៥] មាត្រា២៥ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ

[៦] មាត្រា២៦ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ

[៧] មាត្រា២៨ នៃក្រមព្រហ្មទណ្ឌ

ទៅនឹងចារីផងដែរ។

ឧទាហរណ៍៖ បុគ្គល ក បានយកកាំបិតទៅចាក់សម្លាប់បុគ្គល ង ដោយក្នុងនោះមានបុគ្គល ខ និង គ បានចូលរួមសកម្មភាពដោយបានចាប់ដៃ ចាប់ជើង និងវាយដំលើបុគ្គល ង ។

ដោយបុគ្គល ក ខ និងគ បានទទួលការបញ្ជា(ជួល)ពីបុគ្គល ច អោយសម្លាប់បុគ្គល ង ពីព្រោះបុគ្គល ច និងបុគ្គល ង មានទំនាស់នឹងគ្នា ។ ដូចនេះបុគ្គល ច ត្រូវបានចាត់ទុកជាអ្នកផ្តើមគំនិត ឬចារីបញ្ញា ដែលបានគិត និងជាឬសគល់បង្កឱ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺបទល្មើសមនុស្សឃាត។

**១.១.៥ អ្នកសមគំនិត**

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណា ដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចនូវបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។[៨]

អ្នកសមគំនិត គឺជាអ្នកដែលជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសអោយកើតមានឡើង តាមរយៈនៃការផ្តល់ជាជំនួយ ការឧបត្ថម្ភជាសម្ភារៈ ឬមធ្យោបាយផ្សេងៗ ។ បានន័យថាអ្នកសមគំនិត គឺមិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ទេ តែជាអ្នកដែលបានដឹងលឺនិងជាចំណែកមួយដើម្បីសម្រួលឱ្យមានភាពងាយស្រួលដល់ការប្រព្រឹត្តនូវបទល្មើស។ ទោះបីអ្នកសមគំនិតមិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ ក៏ច្បាប់បានកំណត់ផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

ឧទាហរណ៍៖ បុគ្គល ក ខ និងគ បានទទួលការបញ្ជា(ជួល)ពីបុគ្គល ច អោយសម្លាប់បុគ្គល ង ពីព្រោះបុគ្គល ច និងបុគ្គល ង មានទំនាស់នឹងគ្នា ។ ដើម្បីសម្រេចបានតាមការបញ្ជា ឬសម្លាប់បុគ្គល ង ឱ្យបានជោគជ័យ បុគ្គល ក បានធ្វើទំនាក់ទំនងជាមួយបុគ្គល ឃ។ បុគ្គល ឃ បានឱ្យកាំបិតទៅបុគ្គល ក ដើម្បីធ្វើសកម្មភាពសម្លាប់ជនរងគ្រោះ។

ដូចនេះបុគ្គល ឃ ត្រូវបានចាត់ទុកជាអ្នកសមគំនិត ដោយបានសម្រួល និងផ្តល់ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺបទល្មើសមនុស្សឃាត។

នៅក្នុងឧទាហរណ៍ខាងលើ បានធ្វើឱ្យមានការកំណត់យ៉ាងច្បាស់ពីឋានៈរបស់បុគ្គលនីមួយៗ។ បុគ្គល ក ជាចារី បុគ្គល ខ គ ជាសហចារី បុគ្គល ឃ ជាអ្នកសមគំនិត និងបុគ្គល ង ជាអ្នកផ្តើមគំនិត ឬចារីបញ្ញា។ ទោះស្ថិតក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគមនិត ឬអ្នកសមគំនិត ក៏ពួកគេត្រូវបានទទួលទោសផ្នែកព្រហ្មទណ្ឌក្នុងបទល្មើសដូចគ្នាដែរ។

[៨] មាត្រា២៩ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ

## ១.២ ភាគីជារដ្ឋ

ទំនាក់ទំនងសង្គមដែលត្រូវបានច្បាប់ព្រហ្មទណ្ឌ(ក្រមព្រហ្មទណ្ឌ)សម្របសម្រួល ដែលនៅក្នុងនោះមានប្រធានទំនាក់ទំនងពីរមានសិទ្ធិនិងកាតព្វកិច្ចខាងផ្លូវច្បាប់ខុសគ្នា ប៉ុន្តែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា។

រដ្ឋ គឺជាប្រធានមួយក្នុងចំណោមប្រធាននៃទំនាក់ទំនងនេះតាមរយៈស្ថាប័នជំនាញរបស់ខ្លួន គឺស្ថាប័នស៊ើបអង្កេត អយ្យការ និងតុលាការ ដើម្បីធ្វើការចោទប្រកាន់ និងវិនិច្ឆ័យទោសជនល្មើស ចាប់ខ្លួនជនល្មើសមកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងទទួលទោសតាមច្បាប់កំណត់អំពីបទល្មើសដែលជននោះបានប្រព្រឹត្ត។

### ១.២.១ នគរបាលយុត្តិធម៌

**នគរបាលយុត្តិធម៌** ជាអ្នកថែរក្សា ការពារសណ្តាប់ធ្នាប់ក្នុងសង្គម។ ក្នុងន័យច្បាប់នគរបាលយុត្តិធម៌ គឺជាជំនួយដល់តុលាការ[៩]។ នគរបាលយុត្តិធម៌ មានភារកិច្ចត្រួតពិនិត្យបទល្មើស កំណត់អត្តសញ្ញាណជនល្មើស និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។[១០] សមាសភាពនគរបាលយុត្តិធម៌មានដូចជាមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ ភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។[១១]

### ១.២.២ ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញា** គឺជាអ្នកដឹកនាំ និងសម្របសម្រួលរាល់សកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងរង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួន។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ហើយអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌នឹងរៀបចំឱ្យមានអ្នកជំនួស។[១២]

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីគឺ ៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានប្រព្រឹត្តិបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលបានសង្ស័យថាបានប្រព្រឹត្តិបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តិបទល្មើស។[១៣]

---

[៩] មាត្រា៥៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១០] មាត្រា៥៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១១] មាត្រា៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១២] មាត្រា៣៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១៣] មាត្រា៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ១.២.៣ ចៅក្រមស៊ើបសួរ

**ចៅក្រមស៊ើបសួរ** គឺជាអ្នកដែលស្វែងរកការពិត ព្រោះតួនាទីសំខាន់របស់ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនត្រូវចោទ ជាបណ្ដោះអាសន្ន ដែលនេះ ជាសេចក្ដីសម្រេចមានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិ សេរីភាពរបស់បុគ្គល។[១៤]

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចដែនដីគឺ៖

- ចៅក្រមស៊ើបសួរនៃទីកន្លែងប្រព្រឹត្តិបទល្មើស
- ចៅក្រមស៊ើបសួរនៃទីលំនៅរបស់ជនដែលបានសង្ស័យថាបានប្រព្រឹត្តិបទល្មើស
- ចៅក្រមស៊ើបសួរនៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តិបទល្មើស។[១៥]

### ១.២.៤ ចៅក្រមជំនុំជម្រះ

ក្នុងន័យនេះចៅក្រមជំនុំជម្រះ សម្ដៅដល់តុលាការ ដែលមានសមត្ថកិច្ច ក្នុងការជំនុំជម្រះក្ដីផ្ដល់ភាពយុត្តិធម៌។ ចៅក្រមជំនុំជម្រះនឹងចាប់ផ្ដើមនីតិវិធីបន្ទាប់ពីដំណាក់កាលស៊ើបសួរត្រូវបានបញ្ចប់។

តុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្នុងរឿងក្ដីព្រហ្មទណ្ឌគឺ

- តុលាការនៃទីកន្លែងបទល្មើស
- តុលាការនៃលំនៅឋានរបស់ជនជាប់ចោទ
- តុលាការនៃទីកន្លែងចាប់ខ្លួនជនជាប់ចោទ។[១៦]

## ១.៣ ភាគីពាក់ព័ន្ធដទៃទៀត

ក្រៅពីភាគីជាជនល្មើស និងភាគីជារដ្ឋហើយ យើងក៏មានភាគីមួយទៀតគឺភាគី ដែលជាអ្នកជាប់ពាក់ពន្ធ័ដទៃទៀតផងដែរ ដូចជា មេធាវី និងសាក្សីជាដើម។

### ១.៣.១ មេធាវី

**មេធាវី** គឺជាវិជ្ជាជីវៈមួយ ដែលមានលក្ខណៈឯករាជ្យ និងសេរីត្រូវបានបង្កើតឡើងដើម្បីចូលរួមបម្រើវិស័យយុត្តិធម៌ ហើយវិជ្ជាជីវៈនេះអាចប្រព្រឹត្តទៅបានតែក្នុង ក្របខ័ណ្ឌនៃគណៈមេធាវីតែប៉ុណ្ណោះ នេះបើយោងតាមមាត្រា១ នៃច្បាប់ ស្ដីពីលក្ខន្តិកៈមេធាវី។ មេធាវីអាចតំណាងកូនក្ដីក្នុងរឿងក្ដីរដ្ឋប្បវេណីតាមការយល់ព្រមពីកូនក្ដី តាមរយៈលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិនៅគ្រប់សាលាជម្រះក្ដី និងគ្រប់ដំណាក់កាល

[១៤] រុនពណ្ណារិទ្ធ និងចាំង ស៊ីណាត,២០១៣-- ២០១៤

[១៥] មាត្រា១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១៦] មាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នៃនីតិវិធី លើកលែងតែមានបទបញ្ញត្តិច្បាប់ចែងផ្ទុយពីនេះជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច។[១៧] នៅក្នុងរឿងក្តីខាងលើនេះ មេធាវីដើរតួនាទីយ៉ាងសកម្មក្នុងការស្វែងរកភស្តុតាងបង្ហាញជូនតុលាការ។

មេធាវីអាចការពារសិទ្ធិជនសង្ស័យ ជនត្រូវចោទ និងជនចាប់ចោទ តាមរយៈពាក្យសុំពឹងពាក់មេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌ ប៉ុន្តែមេធាវីមិនអាចតំណាងជនទាំងនោះបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈពាក្យសុំពឹងពាក់ និងប្រគល់សិទ្ធិ។ មេធាវីជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ។[១៨]

តួនាទីរបស់មេធាវីមានដូចជា៖

- មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត។
- មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី ឬចៅក្រមឲ្យបំពេញមុខងារជាអ្នកផ្សះផ្សារ ជាអ្នកសម្របសម្រួល។
- មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាលបាន លុះត្រាតែមានច្បាប់អនុញ្ញាត។[១៩]
- ផ្សព្វផ្សាយច្បាប់ ដើម្បីប្រជាពលរដ្ឋយល់ដឹងទូលំទូលាយ និងគាំទ្រការគោរពសិទ្ធិមនុស្ស។

### ១.៣.២ សាក្សី

**សាក្សី** គឺជាមនុស្សដែលអាចផ្តល់ព័ត៌មានឬរឿងរ៉ាវដោយផ្ទាល់និងពិតប្រាកដ ទាក់ទងនឹងការស៊ើបអង្កេត និងការកាត់ក្តីនានាដែលស្ថិតនៅក្នុងអាណាត្តិរបស់តុលាការ។ អ្នកទាំងនោះអាចជាជនរងគ្រោះ ឬជាមនុស្សណាម្នាក់ដែលមានព័ត៌មានទាក់ទងបទឧក្រិដ្ឋនោះ។ រឿងរ៉ាវជាក់ស្តែងដែលបុគ្គលនោះរៀបរាប់ មានតម្លៃស្មើនឹងភ័ស្តុតាង។ ភ័ស្តុតាងដែលផ្តល់ដោយសាក្សីក្នុងអំឡុងពេលស៊ើបអង្កេត នឹងក្លាយទៅជាផ្នែកមួយនៃសំណុំរឿង ឬប្រសិនបើត្រូវបានផ្តល់ឲ្យក្នុងពេលកាត់ក្តី ភ័ស្តុតាងនោះនឹងក្លាយទៅជាឯកសារផ្លូវការនៃសវនាការ។ អ្នកណាក៏ដោយដែលត្រូវចាត់ទុកថាជាមនុស្សសំខាន់សម្រាប់ផ្តល់ការពិតក្នុងពេលស៊ើបអង្កេតនិងពេលកាត់ក្តីអាចនឹងត្រូវសុំឲ្យផ្តល់ភ័ស្តុតាង រាប់បញ្ចូលទាំងអ្នកជំនាញផងដែរ។

សាក្សីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការឆ្លើយឱ្យការរបស់ខ្លួន។ ការផ្តល់សក្ខីកម្មក្លែងក្លាយគឺជាបទល្មើសព្រហ្មទណ្ឌ។សក្ខីកម្មភូតកុហកដែលធ្វើក្រោយពីបានស្បថ នៅមុខតុលាការ ឬនៅមុខមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសកម្មភាពក្នុងក្របខណ្ឌដីកាចាត់ឱ្យសួរចម្លើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ២ ទៅ ៥ឆ្នាំ

[១៧] មាត្រា២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកមេធាវី
[១៨] មាត្រា២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកមេធាវី
[១៩] មាត្រា៣ នៃច្បាប់ស្តីពីលក្ខន្តិកមេធាវី

និងពិន័យជាប្រាក់ពី៤លានរៀល ទៅ ១០លានរៀល។[២០] ប៉ុន្តែមាត្រា ៥៤៥ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ លើកលែងឱ្យសាក្សីភូតកុហករួចផុតពីទោស ប្រសិន បើសាក្សីប្រែក្រឡាស់ដោយឯកឯងនូវសក្ខីកម្មរបស់ខ្លួន ហើយនិយាយតែការពិតមុនសេចក្តីសម្រេចបញ្ចប់នីតិវិធីស៊ើបសួរ ឬនីតិវិធីជំនុំជម្រះ។

ក្រមព្រហ្មទណ្ឌានបទបញ្ញត្តិជាច្រើនដែលដាក់កាតព្វកិច្ចលើសាក្សីឱ្យផ្តល់សក្ខីកម្មដល់តុលាការ ដើម្បី ស្វែងរកការពិត ។ ចំពោះការមិនព្រមចូលខ្លួនតាមដីកាកោះហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬ ចៅក្រមស៊ើបសួរ ឬ តុលាការព្រហ្មទណ្ឌ ដោយគ្មានមូលហេតុសមស្រប នោះសាក្សីនឹងប្រឈមនឹងបទល្មើស ព្រហ្មទណ្ឌ។ រាល់បុគ្គលណាដែលត្រូវបានកោះ ហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬ មុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី១០០០០០(មួយសែន)រៀល ទៅ ១០០០០០០(មួយលាន)រៀល។[២១]

ជាងនេះទៅទៀត សាក្សីដែលមានភស្តុតាងបង្ហាញឱ្យឃើញភាពស្លូតត្រង់របស់ជនត្រូវចោទ ជន ជាប់ចោទ ពិរុទ្ធជន ឬទណ្ឌិត ហើយមិនផ្តល់ភស្តុតាងនានាដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេង ទៀតទេ ត្រូវមានទោសពីបទល្មើស មិនផ្តល់ភស្តុតាងនៃភាពគ្មានទោស ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី២០០០០០០(ពីរលាន) ទៅ៦០០០០០០(ប្រាំមួយលាន) រៀល។[២២]

ដូចនេះសាក្សីមានសិទ្ធិ និងកាតព្វកិច្ចជាច្រើនដែលច្បាប់បានតម្រូវយ៉ាងច្បាស់ ដើម្បីជាប្រយោជន៍ ដល់គ្រប់ភាគី។

[២០] មាត្រា ៥៤៥ នៃក្រមព្រហ្មទណ្ឌ

[២១] មាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ

[២២] មាត្រា ៥៣៩ នៃក្រមព្រហ្មទណ្ឌ

# ជំពូកទី២
# សិទ្ធិរបស់ជនល្មើសក្នុងរឿងក្ដីព្រហ្មទណ្ឌ

# ជំពូកទី២

# សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ

## ២.១ សិទ្ធិទទួលបានជំនួយផ្នែកច្បាប់

នៅក្នុងប្រទេសកម្ពុជាកាលណាមានទំនាស់កើតឡើង និងមានការប្តឹងទៅប៉ូលីសឬប្តឹងទៅតុលាការ។ ការឃុំខ្លួន ឬចាប់ខ្លួនតែងតែកើតមានឡើងនៅពេលមានពាក្យបណ្តឹង ដោយសារមានការប្រព្រឹត្តបទល្មើសជាក់ស្តែង។ អាជ្ញាធរអាចឃុំខ្លួន ឬចាប់ខ្លួន តែចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងមជ្ឈិមដែលដាក់គុកពីមួយឆ្នាំឡើងទៅប៉ុណ្ណោះ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៦ បានបញ្ញត្តថា មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឃាត់ខ្លួន ចំពោះបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។ កាឃាត់ខ្លួនមានថិរវេលា ៤៨ ម៉ោង ( ចាប់គិតទាំងពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុហត្ថ )។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ក៏ អាចពន្យាពេលថែម ២៤ ម៉ោងទៀតផងដែរក្នុងករណីដែលរកឃើញថាមានភស្តុតាងថ្មីដែលមានប្រយោជន៍ដល់រឿងក្តី តែការពន្យាពេលមិនត្រូវអនុញ្ញាតឱ្យលើសពី ២៤ ម៉ោងនេះទេ។ នៅពេលឃាត់ខ្លួន ជនជាប់ឃុំនឹងត្រូវបាត់បង់នូវសិទ្ធិមួយចំនួនដែលមិនដូចនឹងបុគ្គលទូទៅទេ តែវាមិនមានបានន័យថាជនជាប់ឃុំបាត់បង់នូវសិទ្ធិទាំងអស់នោះទេ សិទ្ធិមួយចំនួនជនជាប់ឃុំ នៅតែទទួលបាន ដោយមានចែងក្នុងច្បាប់ ដូចជានៅក្នុងច្បាប់ស្តីពីពន្ធនាគារ មាត្រា ២០ ដែលបញ្ញត្តថា ជនជាប់ឃុំមានសិទ្ធិស្វែករកអ្នកតំណាងផ្នែកច្បាប់ សិទ្ធិផ្តល់ដំណឹងទៅគ្រួសារ ឬសាច់ញាតិ ឬស្ថាប័នពាក់ពន្ធផ្សេងៗទៀត អំពីការជាប់ពន្ធនាគារ និង ទីតាំងនៃពន្ធនាគារ ព្រមទាំងសិទ្ធិ និងករណីកិច្ចផ្សេងៗទៀត។ ប៉ុន្តែក៏មានសិទ្ធិផ្សេងទៀតដែរ ដែលជនជាប់ឃុំទទួលបានក្នុងករណីពិសេស ដូចជាសិទ្ធិទទួលបាន គ្រូពេទ្យ[២៣] និងសិទ្ធិទទួលបានអ្នកបកប្រែ[២៤]ផងដែរ។



[២៣] មាត្រា ៩៩ នៃក្រមនីតិវិធិព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[២៤] មាត្រា ៩៣ ចំណុច៣ នៃក្រមនីតិវិធិព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.១.១ សិទ្ធិស្នើសុំមេធាវី

នៅពេលដែលបញ្ជូនខ្លួនជនជាប់ឃុំមកដល់ពន្ធនាគារ មន្ត្រីពន្ធនាគារត្រូវពន្យល់អំពីសិទ្ធិនិងកាតព្វកិច្ច ដូចដែលមានចែងនៅក្នុងច្បាប់ រួមទាំងការពន្យល់អំពីបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងការដាក់ពិន័យចំពោះជនណាដែលប្រព្រឹត្តខុសពីបទបញ្ជាផ្ទៃក្នុងនៃពន្ធនាគារ។ មុនពេលដែលជនជាប់ឃុំ ត្រូវបានបញ្ជូលខ្លួនមកដល់ពន្ធនាគារ ជនជាប់ឃុំធ្លាប់ជាជនជាប់ចោទ ដែលធ្វើការឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាធរពាក់ពន្ធផ្សេងទៀត ដែលនៅក្នុងដំណាក់កាល ឃាត់ខ្លួននេះ ជនជាប់ឃុំមានសិទ្ធិស្នើសុំមេធាវី ដើម្បីការពារខ្លួន។

នៅក្នុងក្របខណ្ឌនៃការការពារខ្លួនរបស់ជនត្រូវចោទ នៅក្នុងនីតិវិធីស៊ើបសួរ ជនត្រូវចោទអាចទទួលជំនួយពីមេធាវីបានគ្រប់ពេល។ ក្នុងរយះពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលចាប់ផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលត្រូវឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននោះមានការទាក់ទិននៅក្នុងរឿងក្តីជាមួយគ្នា។[២៥] ជនជាប់ចោទត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសតាមគ្រប់មធ្យោបាយ និងជាបន្ទាន់។មេធាវី ដែលជនជាប់ចោទអាចទទួលជំនួយបាននៅក្នុងការការពារសិទ្ធិ នៅក្នុងដំណើរការនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌនេះតាមពីររបៀប គឺមេធាវីដែលជនត្រូវចោទបានពឹងពាក់ដោយខ្លួនឯង ហើយបង់ថ្លៃកម្រៃសេវាមេធាវី សម្រាប់ការពារសិទ្ធិរបស់ខ្លួនក្នុងដំណើរការនីតិវិធី ក្នុងរឿងក្តីព្រហ្មទណ្ឌ ប៉ុន្តែប្រសិនបើក្នុងករណីដែលជនត្រូវចោទមិនមានលទ្ធភាពក្នុងការជួលមេធាវី ដើម្បីការពារសិទ្ធិរបស់ខ្លួននោះទេ តុលាការ ឬ ជនត្រូវចោទផ្ទាល់អាចដាក់ពាក្យសុំទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យចាត់មេធាវីការពារជនក្រីក្រដោយមិនគិតថ្លៃកម្រៃសេវាមេធាវីឡើយ។ មេធាវីដែលនឹងត្រូវចាត់មកនេះគឺជាសមាជិកនៃក្រុមគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់ ដោយស្របទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។

នៅក្នុងករណីដែលជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរឃុំខ្លួន នៅក្នុងពន្ធនាគារ ឬមណ្ឌល ឃុំខ្លួនណាមួយ មេធាវីរបស់ជនត្រូវចោទអាចប្រាស្រ័យទាក់ទងជាមួយកូនក្តីរបស់ខ្លួនក្នុងពន្ធនាគារ ក្នុងមណ្ឌលឃុំខ្លួននោះ។[២៦] មេធាវី និង ជនត្រូវចោទដែលជាកូនក្តីរបស់ខ្លួន អាចធ្វើការសន្ទនាគ្នា ក្នុងបន្ទប់សន្ទនានៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ហើយការសន្ទនារវាងមេធាវី និង ជនត្រូវចោទ គឺធ្វើឡើងដោយសម្ងាត់ ដោយមិនត្រូវបានគេស្តាប់បានឡើយ។ ក្នុងករណីដែលជនត្រូវចោទបានសារភាពនូវកំហុសរបស់ខ្លួនថាបានប្រព្រឹត្តបទល្មើសពិតមែន តតិយជនដែលលួចថតសម្លេងបាននោះ ហើយនគរបាល ឬ តតិយជននោះ យកមកធ្វើជាភស្តុតាង ក្នុង

[២៥] មាត្រា ៩៨ នៃក្រមនីតិវិធិព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[២៦] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គោលបំណងដើម្បីឱ្យតុលាការសម្រេចផ្តន្ទាទោស ដល់ជនត្រូវចោទនោះ។ ភស្តុតាងនោះគឺ មិនអាចយកមកធ្វើជាមូលដ្ឋាននៅក្នុងសេចក្តីដាក់បន្ទុកទៅលើជនត្រូវចោទ ឬមិនអាចសម្រេចសេចក្តីផ្តន្ទាទោសជនជាប់ចោទបាននោះទេ។ មេធាវី អាចអានលិខិតសំណុំរឿងឱ្យកូនក្តីស្តាប់បាន ប៉ុន្តែមេធាវីមិនអាចថតចម្លងលិខិត សំណុំរឿងទាំងនោះទៅឱ្យជនត្រូវចោទនោះទេ។ ចំពោះការសន្ទនាជាមួយមេធាវី ជនជាប់ចោទ អាចធ្វើឡើងបាន ២ វិធីដូចជា

- ការផ្ញើលិខិត
- ការជួបពិភាក្សាជាសម្ងាត់ជាមួយមេធាវី។

រាល់ទំនាក់ទំនងរវាង ជនជាប់ឃុំ និងមេធាវីត្រូវបានធ្វើឡើងដោយការសម្ងាត់[២៧]។



### ២.១.២ សិទ្ធិទទួលបានគ្រូពេទ្យ

សុខភាពល្អមានសារៈសំខាន់ណាស់ សម្រាប់មនុស្សគ្រប់រូប។ សុខភាពនេះជះឥទ្ធិពលលើអាកប្បកិរិយា និងសមត្ថភាពក្នុងការបំពេញមុខងារ។ សុខភាពល្អមានសារៈសំខាន់ជាពិសេសក្នុងពន្ធនាគារដែលជាសហគមន៍មួយបិទជិត។ ជាធម្មតាការដាក់ពន្ធនាគារ អាចបង្កផលប៉ះពាល់អវិជ្ជមានដល់សុខមាលភាពរបស់ជនជាប់ឃុំ ទាំងផ្លូវកាយ និងផ្លូវចិត្ត។ រដ្ឋបាលពន្ធនាគារមិនត្រឹមតែផ្តល់ការថែទាំសុខភាពប៉ុណ្ណោះទេ តែថែមទាំងបង្កើតលក្ខខណ្ឌដែលលើកកម្ពស់សុខមាលភាពទាំងជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ។ ជនជាប់ឃុំមិនគួរចាកចេញពីពន្ធនាគារ ក្នុងស្ថានភាពសុខភាពយ៉ាប់យឺនជាងពេលដែលពួកគេបានចូលមកនោះទេ។ លក្ខខណ្ឌតម្រូវ

---

[២៧] មាត្រា ៣១ កថាខណ្ឌ ២ នៃច្បាប់ស្តីពីពន្ធនាគារ

នេះអនុវត្តគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅក្នុងពន្ធនាគារ ជាពិសេសលើការថែទាំសុខភាព។ ជនជាប់ឃុំនៅតែមានសិទ្ធិមូលដ្ឋានក្នុងទទួលបានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយក៏មានសិទ្ធិទទួលបានការថែរក្សាសុខភាពតាមបទដ្ឋានមួយ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងការផ្ដល់សេវាសុខភាពដល់ប្រជាជនទូទៅដែរ ។ ជនជាប់ឃុំ ឬជនជាប់ពន្ធនាគារ ត្រូវទទួលបានការត្រួតពិនិត្យសុខភាពឲ្យបានត្រឹមត្រូវ និងឆាប់រហ័សតាមដែលអាចធ្វើបាន បន្ទាប់ពីចូលមកដល់មន្ទីរឃុំឃាំង ឬពន្ធនាគារ ហើយការថែទាំ និងការព្យាបាលបែបវេជ្ជសាស្ត្រ ត្រូវតែផ្ដល់ឲ្យជននោះពេលពួកគេត្រូវការ និងការព្យាបាល ត្រូវតែផ្ដល់ឱ្យដោយឥតគិតថ្លៃ។ ហើយនេះជាកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា។

ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ ពេលវេលា។[២៨] គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះសមស្របនឹងការឃាត់ខ្លួនដែរ ឬទេ។ ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ ចំណែកឯគ្រូពេទ្យត្រូវចេញវិញ្ញាបនបត្របញ្ជាក់សុខភាព ដែលភ្ជាប់មកជាមួយសំណុំរឿង។ មន្ត្រីនគរបាលយុត្តិធម៌នឹងចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាព។ ហើយព្រះរាជអាជ្ញាក៏អាចចុះទៅកាន់កន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់មើលលក្ខខណ្ឌនៃការឃាត់ខ្លួនផងដែរ។ ការពិនិត្យបែបនេះ គឺដើម្បីពិនិត្យរកមើលជំងឺផ្លូវកាយ ឬផ្លូវចិត្ត និងចាត់វិធានការចាំបាច់ ដូចជាដាក់ជនជាប់ឃុំណាដែលគេសង្ស័យថាមានកើតជំងឺឆ្លង ឬមានលក្ខណៈឆ្លង ឱ្យនៅដាច់ដោយឡែកពីគេ ឬដើម្បីធ្វើការកត់សំគាល់អំពីលក្ខណៈមិនគ្រប់គ្រាន់ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការស្តារនីតិសម្បទា កំណត់អំពីកាយសម្បទារបស់ជនជាប់ឃុំសំរាប់ធ្វើការ។





[២៨] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ២.១.៣ សិទ្ធិទទួលបានព័ត៌មាន

សិទ្ធិទទួលពត៌មាន ជាសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបាន នូវព័ត៌មានពីស្ថាប័នសាធារណៈទាំងឡាយ ហើយសិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់។ សិទ្ធិទទួលព័ត៌មាន ជាឧបករណ៍ដ៏សំខាន់មួយដែលធានាការបើកចំហ និងតម្លាភាព សម្រាប់លើកស្ទួយអភិបាលកិច្ចល្អ និងធ្វើការកាត់បន្ថយអំពើពុករលួយ។ ព័ត៌មានទាំងនោះត្រូវតែជាព័ត៌មានដែលពិស្តារ និងជាព័ត៌មានទាន់ពេលវេលា អំពីប្រភេទ មូលហេតុ ខ្លឹមសារនៃការចោទប្រកាន់ ឬក៏បញ្ហានានាដែលកើតឡើងទាក់ទងនឹងជនជាប់ឃុំ។

ជនជាប់ឃុំមានសិទ្ធិទទួលបានព័ត៌មានដូចជា បុគ្គលទូទៅដែរ ព្រោះអីជនជាប់ឃុំក៏ត្រូវបាន អនុញ្ញាតឱ្យទទួលបានដំណឹង ឬព័ត៌មានសំខាន់ៗនានា តាមរយៈកម្មវិធីប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗដូចជា វិទ្យុ ទូរទស្សន៍ ទស្សានាវដ្ដី និងការទំនាក់ទំនងទូរសព្ទ័ជាមួយគ្រួសារ ដែលរៀបចំឡើងដោយពន្ធនាគារ។[២៩]

មួយទៀតជនជាប់ឃុំ ក៏អាចអនុញ្ញាតឱ្យចូលសិក្សាស្រាវជ្រាវក្នុងបណ្ណាល័យពន្ធនាគារ ឬអនុញ្ញាតឱ្យខ្ចីសៀវភៅយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង។[៣០] ចំពោះគ្រួសារ ឬសាច់ញាតិជនជាប់ឃុំ នឹងត្រូវបានការជូនដំណឹងទាក់ទង់ អំពីការឈឺ ឬទទួលមរណៈភាពដោយមន្ត្រីពន្ធនាគារឱ្យបានដឹងទៅវិញទៅមក។[៣១]



[២៩] មាត្រា ៣៧ កថាខណ្ឌ ១ នៃច្បាប់ស្ដីពីពន្ធនាគារ

[៣០] មាត្រា ៣៧ កថាខណ្ឌ ២ នៃច្បាប់ស្ដីពីពន្ធនាគារ

[៣១] មាត្រា ៣៧ កថាខណ្ឌ ៣ នៃច្បាប់ស្ដីពីពន្ធនាគារ

## ២.២ សិទ្ធិទទួលបានការស៊ើបអង្កេតដោយត្រឹមត្រូវនិងយុត្តិធម៌

សិទ្ធិទទួលបានការស៊ើបអង្កេតដោយត្រឹមត្រូវនិងយុត្តិធម៌ ជាសិទ្ធិមួយដ៏សំខាន់ក្នុងដំណើរការ នៃរឿងក្តីព្រហ្មទណ្ឌដើម្បី សម្រេចបាននូវភាពសុក្រឹត្រ ត្រឹមត្រូវ មិនលំអៀង និងភាពយុត្តិធម៌។ ក្នុងដំណាក់កាលដ៏សំខាន់នេះ ជនជាប់ចោទ ក៏មានសិទ្ធិជាមូលដ្ឋានមួយចំនួនបន្ថែមទៀតរួមមានដូចជា សិទ្ធិទទួលដឹងពីប្រភេទ និងបុព្វហេតុនៃការចោទប្រកាន់ សិទ្ធិទទួលបានការសួរចម្លើយតាមច្បាប់គ្មានអំពើហិង្សា ទណ្ឌកម្ម និងអំពើអមនុស្សធម៌ សិទ្ធិទទួលដឹងពី ភស្តុតាង សាក្សី សិទ្ធិទទួលបានការនៅក្រៅឃុំ និងលក្ខខណ្ឌរបស់ជនជាប់ឃុំ។

### ២.២.១ សិទ្ធិទទួលដឹងពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់

ជនជាប់ចោទត្រូវមានសិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងបុព្វហេតុនៃការចោទប្រកាន់ នៅក្នុងដំណាក់កាលទាំងមុន និងក្នុងអំឡុងពេលជំនុំជម្រះ។ ការអនុវត្តសិទ្ធិនេះ មានសារៈសំខាន់ណាស់ដើម្បី ៖

- ធានាថា ជនជាប់ចោទយល់ដឹងពីមូលហេតុដែលខ្លួនត្រូវបានចោទប្រកាន់
- ធានាថា ជនជាប់ចោទអាចតបតទៅនឹងការឃុំខ្លួនណាមួយដែលអាចនឹងកើតមានឡើង
- ធានាថា ជនជាប់ចោទមានឱកាសការពារក្តីតាមដែលអាចធ្វើទៅបាន តបទៅនឹងការចោទប្រកាន់
- ការពារប្រឆាំងនឹងការចោទប្រកាន់ដែលគ្មានមូលដ្ឋានច្បាស់លាស់

**ដំណាក់កាលមុនជំនុំជម្រះ**

ជនជាប់ចោទមុននឹងត្រូវបាននាំខ្លួនមកកាន់សវនាការ ត្រូវតែទទួលបានព័ត៌មានភ្លាមៗ និងយ៉ាងលម្អិតជាទីបំផុតអំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់ប្រឆាំងនឹងខ្លួន។[៣២] សិទ្ធិនេះហើយដែលជាមូលដ្ឋានក្នុងការទាមទារ និងផ្តល់ឱ្យជនជាប់ចោទទទួលបាននូវពេលវេលា និងសម្ភារៈគ្រប់គ្រាន់ដើម្បីរៀបចំសម្រាប់ការពារខ្លួនទៅនឹងបទចោទប្រកាន់។ ជនជាប់ចោទ គួរត្រូវបានពន្យល់អំពីច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធ និងសិទ្ធិផ្សេងៗនៅមុនពេលសវនាការ ដែលនេះជាកាតព្វកិច្ចរបស់អយ្យការ។

**ដំណាក់កាលជំនុំជម្រះ**

ដើម្បីអនុវត្តកាតព្វកិច្ចដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចៅក្រមជំនុំជម្រះត្រូវតែ ៖

- ប្រកាសសំណុំរឿងដែលត្រូវជំនុំជម្រះ

[៣២] មាត្រា ១៤(៣.ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

- ពន្យល់អំពីបទចោទប្រកាន់ ដោយរួមបញ្ចូលទាំងកាលបរិច្ឆេទ និងទីកន្លែងដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ៖ ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។[៣៣] នេះជាការចាំបាច់ដែលត្រូវបំពេញ ដើម្បីធានាថាជនជាប់ចោទ ឬអ្នកតំណាងរបស់ជនជាប់ចោទ បានទទួលព័ត៌មានត្រឹមត្រូវ។
- ប្រកាសអំពីភាគីពាក់ព័ន្ធ ៖ ក្រឡាបញ្ជីត្រូវហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណជនទាំងនោះ។[៣៤] ការបង្ហាញអត្តសញ្ញាណភាគីពាក់ព័ន្ធ ដើម្បីធានាថា ជនជាប់ចោទពិតប្រាកដត្រូវបាននាំខ្លួនមកកាន់តុលាការ និងជនជាប់ពាក់ព័ន្ធដទៃទៀតមានវត្តមាននៅក្នុងសវនាការ។



(មុនជំនុំជម្រះ)



(កំឡុងពេលជំនុំជម្រះ)

[៣៣] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣៤] មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ២.២.២ សិទ្ធិទទួលបានការសួរចម្លើយតាមច្បាប់គ្មានអំពើហិង្សា ទណ្ឌកម្ម និងអំពើអមនុស្សធម៌

លិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ឬច្បាប់ជាតិបានចែងយ៉ាងច្បាស់ថាទោះបី ស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនអាចទទួលយកការធ្វើទារុណកម្ម ឬទណ្ឌកម្ម ក្នុងវិធីណាមួយដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។ ទារុណកម្ម មានន័យថាអំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំងទោះផ្លូវកាយក្តី ឬផ្លូវចិត្តក្តីដែលបង្កឡើងដោយចេតនាលើជនណាម្នាក់។

ការហាមឃាត់ក្នុងការធ្វើទារុណកម្ម គឺជារឿងមួយចាំបាច់បំផុតជាពិសេសនៅទីកន្លែងសួរចម្លើយ ឬស៊ើបអង្កេត។ ដោយហេតុថា អាចមានការប៉ុនប៉ងគំរាមកំហែងណាមួយដើម្បីទទួលបានព័ត៌មានសំខាន់ៗសម្រាប់ដោះស្រាយសំណុំរឿងក្តីព្រហ្មទណ្ឌ។ ជាក់ស្តែង គឺនៅពេលដែលជនជាប់ចោទសារភាពពីបទល្មើសណាមួយដែលខ្លួនមិនបានធ្វើ ដោយសារតែខ្លួនរងការធ្វើបាបផ្ទាល់ក្នុងអំឡុងពេលស៊ើបអង្កេត ឬសួរចម្លើយ។ ហេតុដូចនេះចម្លើយសារភាពរបស់ជនជាប់ចោទ មិនអាចយកមកធ្វើជាភស្តុតាងនៃរឿងក្តីបានទេ។ ម្យ៉ាងវិញទៀត បើទោះបីជាជនជាប់ចោទមានពិរុទ្ធភាព ពីបទល្មើសក្នុងកម្រិតធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏មិនអាចប្រើអំពើហិង្សាបានឡើយ។



### ២.២.៣ សិទ្ធិទទួលដឹងពីភស្តុតាង សាក្សី

ដើម្បីអាចមានលទ្ធភាពរៀបចំការពារក្តីតទល់នឹងការចោទប្រកាន់ភាគីជនជាប់ចោទ ត្រូវមានសិទ្ធិពិនិត្យមើលភស្តុតាងដែលបានរកឃើញក្នុងអំឡុងពេលស៊ើបអង្កេត និងការវិភាគលើភស្តុតាងដែលបានរៀបចំដោយព្រះរាជអាជ្ញា។ ភាពស្មើគ្នាក្នុងការទទួលបានភស្តុតាង មុនពេលជំនុំជម្រះអាចឱ្យភាគីជនជាប់ចោទវាស់ស្ទង់ស្ថានទម្ងន់នៃភស្តុតាង និងរៀបចំអំណះអំណាងដើម្បីការពារក្តីរបស់ខ្លួនបានល្អពេញលេញ។ សិទ្ធិនេះ មានសារៈសំខាន់ខ្លាំងក្នុងការផ្តល់លទ្ធភាពដល់ជនជាប់ចោទវាយតម្លៃរឿងក្តីរបស់ខ្លួន។

សិទ្ធិដើម្បីអាចត្រួតពិនិត្យសំណុំរឿង មានចែងនៅក្នុងមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សិទ្ធិទទួលដឹងភស្តុតាង រួមមានសិទ្ធិរបស់ភាគីជនជាប់ចោទ ក្នុងការទទួលបានឯកសារពាក់ព័ន្ធនឹងសវនាការ។ សំណុំរឿងជាឯកសារសំខាន់បំផុតរួមមាននូវភស្តុតាងទាំងឡាយ ដែលប្រមូលបានព្រមទាំងដីកាចោទប្រកាន់។ ឯកសារសំណុំរឿងទាំងអស់មានតែទីប្រឹក្សាច្បាប់តែប៉ុណ្ណោះដែលអាចទទួលបាន ហើយត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីដូចមានចែងក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿង នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការ ឲ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។"*
- **មាត្រា ៣៩១ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"អគ្គព្រះរាជអាជ្ញា និងមេធាវីអាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលសវនាការ។"*
- **មាត្រា ១២៩ ១៩៥ ១៩៩ ១៧០ ២៥៩ និង ៥២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។**

**២.២.៤ សិទ្ធិទទួលបានការនៅក្រៅឃុំ**

ការឃុំខ្លួន គឺជាការដកហូតនូវសេរីភាពរបស់បុគ្គល។ ច្បាប់ជាតិ និងអន្តរជាតិ បានចែងអំពីការការពារពីការប្រើប្រាស់ការឃុំខ្លួនទៅលើគ្រប់ករណី លើកលែងតែករណីមួយចំនួនដែលចាំបាច់ និងធ្ងន់ធ្ងរខ្លាំង។

ការឃុំខ្លួនជនត្រូវចោទ (ឃុំខ្លួនបណ្ដោះអាសន្ន) ឬជនជាប់ចោទតាមផ្លូវតុលាការ ជននោះតែងតែស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន។ ប៉ុន្តែជានីតិវិធី តើជនត្រូវចោទ ឬជនជាប់ចោទត្រូវធ្វើបែបណាដើម្បីឲ្យបានត្រឹមត្រូវទៅតាមច្បាប់។

ជនបង្កបទល្មើសដែលត្រូវនគរបាលឃាត់ខ្លួនជានីតិវិធីរបស់នគរបាលយុត្តិធម៌ គឺត្រូវកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត-ក្រុងដែលដំណាក់កាលសាកសួរដំបូងជនសង្ស័យ ត្រូវឆ្លងកាត់ព្រះរាជអាជ្ញា បន្ទាប់មកព្រះរាជអាជ្ញាសាកសួរ និងចោទប្រកាន់។ បន្ទាប់ពីព្រះរាជអាជ្ញាចោទប្រកាន់ចប់ហើយត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរដើម្បីចោទប្រកាន់ ថាតើត្រូវឃុំខ្លួន ឬមិនឃុំខ្លួន? តាមក្នុងដំណាក់កាលនេះ ជនត្រូវចោទមានសិទ្ធិដាក់ពាក្យបណ្ដឹងសុំនៅក្រៅឃុំបាន។ ជនត្រូវចោទអាចស្នើសុំនៅក្រៅឃុំបាន ក៏ប៉ុន្តែការស្នើសុំនៅក្រៅឃុំត្រូវធ្វើជាលិខិតលាយលក្ខណ៍អក្សរនៅដំណាក់កាលចៅក្រមស៊ើបសួរ។

ជនជាប់ចោទ គួរត្រូវទទួលបានសិទ្ធិនៅក្រៅឃុំ ព្រោះការនៅក្រៅឃុំប៉ះពាល់ដល់សេរីភាពបុគ្គលយ៉ាងខ្លាំង។ ច្បាប់បានអនុញ្ញាត ឱ្យមានការប្រើប្រាស់វិធានការណ៍ត្រួតពិនិត្យរបស់តុលាការ ដែលអាចដាក់ទៅលើ ជនជាប់ចោទ នៅខណៈដែលអាចរក្សាបាននូវសេរីភាពរបស់ជននោះ។ ចៅក្រម អាចជ្រើសរើសប្រើប្រាស់វិធានការណ៍មួយ ឬច្រើនជាជម្រើសផ្សេងគ្នាពីការឃុំខ្លួន។[៣៥]



[៣៥] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ២.២.៥ លក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំ

សេចក្តីថ្លៃថ្នូរ និងតម្លៃរបស់ជនជាប់ឃុំគួរត្រូវបានគោរព។ ដើម្បីធានានូវការអនុវត្តលើជនជាប់ឃុំបានត្រឹមត្រូវដោយគោរពតាមគោលការណ៍សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ច្បាប់ស្តីពីពន្ធនាគារបានចង្អុលបង្ហាញ និងបានកំណត់ពីលក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំក្នុងអំឡុងពេលនៃការជាប់ឃុំ។

ទោះបីស្ថិតក្នុងអំឡុងពេលនៃការឃុំខ្លួនក៏ដោយ ជនជាប់ឃុំនៅតែមានសិទ្ធិប្រតិបត្តិសាសនាតាមជំនឿរបស់ខ្លួន និងមិនត្រូវបានបង្ខំឲ្យប្រតិបត្តិសាសនាផ្សេងណាមួយឡើយ។[៣៦]

ជនជាប់ឃុំ ត្រូវឃុំខ្លួនដាច់ដោយឡែកពីគ្នាដោយយោងទៅតាមភេទ អាយុ ប្រវត្តិប្រព្រឹត្តបទល្មើស និងយោងទៅតាមស្ថានភាពចាំបាច់ណាមួយ។

ជនជាប់ឃុំជាបុរស និងជនជាប់ឃុំជាស្ត្រី ត្រូវដាក់ឃុំដាច់ដោយឡែក និងឱ្យបានឆ្ងាយពីគ្នាទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។ អគារឃុំឃាំងជនជាប់ឃុំ ជាស្ត្រីត្រូវមានមន្ត្រីពន្ធនាគារជាស្ត្រី ប្រចាំការជាអចិន្ត្រៃយ៍។ មិនអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារជាបុរសចូលក្នុងតំបន់ជនជាប់ឃុំជាស្ត្រី ដោយគ្មានការអមដំណើរពីមន្ត្រីពន្ធនាគារជាស្ត្រីឡើយលើកលែង តែក្នុងករណីមានឧប្បត្តិហេតុសង្គ្រោះបន្ទាន់ ឬក្នុងហេតុផលសន្តិសុខសុវត្ថិភាពពន្ធនាគារ។[៣៧] ជនជាប់ឃុំដែលមិនទាន់ត្រូវ បានជំនុំជម្រះត្រូវតែដាក់ឱ្យ នៅដាច់ដោយឡែកពីទណ្ឌិត។ ចំណែកជនជាប់ឃុំជាអនីតិជន ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីជនជាប់ឃុំជានីតិជន។

កន្លែងស្នាក់នៅរបស់ជនជាប់ឃុំ ត្រូវស្របទៅតាមតម្រូវការផ្នែកសុខភាព ពោលគឺត្រូវយកចិត្តទុកដាក់ទៅលើបរិយាកាស មានខ្យល់អាកាសចេញចូលគ្រប់គ្រាន់ មានពន្លឺ កម្តៅ និងបន្ទប់មានទំហំសមល្មម។ ក្នុងអំឡុងពេលនោះ ជនជាប់ឃុំដែលមិនតម្រូវឲ្យធ្វើការនៅខាងក្រៅបានឡើយ មុដោយមូលហេតុខាងផ្លូវច្បាប់ ឬមូលហេតុខាងសន្តិសុខ ប៉ុន្តែពួកគេអាចអនុញ្ញាធ្វើឱ្យលំហាត់ប្រាណប្រចាំថ្ងៃបាន។[៣៨] ចំណែកសម្លៀកបំពាក់របស់ជនជាប់ឃុំក៏ ត្រូវមានលក្ខណៈខុសពីទណ្ឌិតដែលកំពុងអនុវត្តទោសក្នុងពន្ធនាគារ ដែលអាចសម្គាល់ និងញែកដាច់រវាងសម្លៀកបំពាក់របស់ជនជាប់ឃុំ និងទណ្ឌិត។

ជនជាប់ឃុំ ត្រូវបានទទួលរបបជីវៈភាព ដែលកំណត់បានដោយអនុក្រឹត្យ។[៣៩] ការផ្តល់អាហារឱ្យដល់ជនជាប់ឃុំ ត្រូវយកចិត្តទុកដាក់គិតគូរអំពីអាហារតមស្របតាមតម្រូវការខាងសុខភាពដែលបញ្ជាក់ពីមន្ត្រី

[៣៦] មាត្រា ២៩ នៃច្បាប់ស្តីពីពន្ធនាគារ

[៣៧] មាត្រា ៣៩ នៃច្បាប់ស្តីពីពន្ធនាគារ

[៣៨] មាត្រា ៣០ នៃច្បាប់ស្តីពីពន្ធនាគារ

[៣៩] មាត្រា ៣៣ នៃច្បាប់ស្តីពីពន្ធនាគារ

ពេទ្យពន្ធនាគារ ឬស្របតាមតម្រូវការខាងសាសនារបស់ពួកគេ។ ជនជាប់ឃុំ អាចទទួល ឬទិញអាហារដោយថវិការផ្ទាល់ខ្លួនពីប្រភពខាងក្រៅបាន តែអាហារទាំងនេះត្រូវបានត្រួតពិនិត្យពីមន្ត្រីពន្ធនាគារជាមុនសិន។[៤០]

ជនជាប់ឃុំ ត្រូវទទួលបានសេវាថែទាំសុខភាពដូចនៅក្រៅឃុំដែលមានលក្ខណស្តង់ដារតែមួយ។ ជនជាប់ឃុំដែលមានជំងឺ ត្រូវបានសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ។ ចំពោះជនជាប់ឃុំមានជំងឺធ្ងន់ហើយតម្រូវឲ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដែលតម្រូវឲ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត តាមសំណើរបស់ជនជាប់ឃុំ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាលត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ។ ចំណែកឯ ជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក។[៤១]

ម្យ៉ាងវិញទៀត ប្រសិនបើជនជាប់ឃុំជាស្ត្រី ត្រូវបានផ្តល់សេវាគាំពារមាតា និងទារកនៅមុន និងក្រោយពេលសម្រាលកូន។ ជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះត្រូវបានអនុញ្ញាតឲ្យសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅ។ ក្នុងករណីមានជនជាប់ឃុំជាស្ត្រីសម្រាលកូនក្នុងពន្ធនាគារ មិនត្រូវចុះសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារទេ។[៤២]

កូនតាមម្តាយ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយត្រឹមអាយុក្រោម ៣ ឆ្នាំ និងត្រូវបានផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព។ ចំណែកឯ កូនត្រូវតាមម្តាយដែលមានអាយុចាប់ពី ៣ (បី) ឆ្នាំ ឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវការចិញ្ចឹមបីបាច់ថែរក្សាបន្តនៅខាងក្រៅទេ នេះជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។[៤៣]

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុទូរទស្សន៍ ទស្សនាវដ្តីសារព័ត៌មាននិងទំនាក់ទំនងទូរសព្ទ ជាមួយក្រុមគ្រួសារដែលរៀបចំឡើងដោយពន្ធនាគារ។

[៤០] មាត្រា ៣៤ នៃច្បាប់ស្តីពីពន្ធនាគារ

[៤១] មាត្រា ៣៨ នៃច្បាប់ស្តីពីពន្ធនាគារ

[៤២] មាត្រា ៤០ នៃច្បាប់ស្តីពីពន្ធនាគារ

[៤៣] មាត្រា ៤១ នៃច្បាប់ស្តីពីពន្ធនាគារ

ជនជាប់ឃុំអាចអនុញ្ញាតឲ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឲ្យខ្ចីសៀវភៅយក ទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើតចំណេះដឹង។ ពន្ធនាគារត្រូវជូនដំណឹងទាក់ទងនឹងជំងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំឲ្យបានដឹងទៅវិញទៅមក។[៤៤]

នៅពេលត្រូវការពិភាក្សាមេធាវី ជនជាប់ឃុំ មានសិទ្ធិទទួល និង ផ្ញើលិខិតឆ្លងឆ្លើយ។ លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំត្រូវបើកនៅចំពោះមុខមន្ត្រីពន្ធនាគារដែលត្រូវបានប្រគល់សិទ្ធិលើកលែងតែលិខិតរបស់មេធាវី។

លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំ ត្រូវបានដកហូត ប្រសិនបើមានការពាក់ព័ន្ធដល់សន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់ទូទៅ ទាំងក្នុង និងក្រៅពន្ធនាគារ។[៤៥] ចំពោះ ជនជាប់ឃុំជាជនបរទេស មានសិទ្ធិទាក់ទងជាមួយស្ថានទូត ឬស្ថានកុលស៊ុល ឬស្ថានតំណាងរបស់ខ្លួន។ រាល់ទំនាក់ទំនងរវាងជនជាប់ឃុំនិងមេធាវី ត្រូវបានធ្វើឡើងដោយសម្ងាត់។[៤៦]

លើសពីនេះទៅទៀត ជនជាប់ឃុំ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភរបស់ជនជាប់ឃុំដូចគ្នា ឬ អំពើរំលោភរបស់មន្ត្រីពន្ធនាគារ។ ពាក្យបណ្តឹងតវ៉ារបស់ជនជាប់ឃុំ ត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ មេធាវីរបស់ជនជាប់ឃុំ ឬតំណាងអយ្យការ ក្នុងរយៈពេលសមស្របណាមួយ។[៤៧]





[៤៤] មាត្រា ៣៧ នៃច្បាប់ស្តីពីពន្ធនាគារ

[៤៥] មាត្រា ៣២ នៃច្បាប់ស្តីពីពន្ធនាគារ

[៤៦] មាត្រា ៣១ នៃច្បាប់ស្តីពីពន្ធនាគារ

[៤៧] មាត្រា ២៨ នៃច្បាប់ស្តីពីពន្ធនាគារ

## ២.៣ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាក់ទងនឹងរឿងសំណុំរឿងព្រហ្មទណ្ឌ គឺតម្រូវឱ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌអ្វីមួយ ទទួលបាននូវការអនុវត្តដោយយុត្តិធម៌ និងស្មើភាពគ្នាក្នុងគ្រាដែលអាជ្ញាធរមានសមត្ថកិច្ចកំណត់ពីពិរុទ្ធភាពរបស់ពួកគេ។ នៅពេលដែលមានការអនុវត្តយ៉ាងត្រឹមត្រូវហើយនោះ ទាំងសិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារ ហើយក៏ធានាអំពីនីតិវិធីយុត្តិធម៌ដ៏ត្រឹមត្រូវផងដែរ។

បើពិនិត្យទៅលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។ **បុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ មានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌។**[៤៨] បានន័យថាដរាបណាដែលតុលាការមិនទាន់ចេញសេចក្តីសម្រេចផ្តន្ទាទោស គឺបុគ្គលនោះត្រូវចាត់ទុកថាជាបុគ្គលគ្មានទោស និងទទួលបានសវនាការយ៉ាងត្រឹមត្រូវ។

សិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ត្រូវបានការពារយ៉ាងជាក់លាក់ក្នុងច្បាប់ជាតិ តាមរយៈរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញជាមូលដ្ឋានគ្រឹះសម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌។ រដ្ឋធម្មនុញ្ញផ្តល់នូវសិទ្ធិ និងការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយធានាថា ៖

- ពុំមានការរំលោភបំពានលើរូបរាងកាយរបស់បុគ្គលណាម្នាក់ឡើយ
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាម្នាក់អាចធ្វើទៅបាន លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តច្បាប់
- ការបង្ខិតបង្ខំការធ្វើបាបរាងកាយ ឬទង្វើណាមួយដែលបន្ថែមទណ្ឌកម្មចំពោះជនជាប់ឃុំ ឬទណ្ឌិតត្រូវបានហាមឃាត់
- ការទទួលសារភាពដែលកើតឡើងពីកាបង្ខិតបង្ខំតាមផ្លូវកាយក្តី ឬផ្លូវចិត្តក្តី មិនត្រូវទទួលយកធ្វើជាភស្តុតាងនៃពិរុទ្ធភាពទេ
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ
- ជនជាប់ចោទ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ
- ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ

[៤៨] មាត្រា ១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានចងក្រងឡើងក្នុងឆ្នាំ២០០៧ ដោយផ្អែកលើគោលការណ៍ចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តយ៉ាងលម្អិតអំពីរបៀបដែលជនសង្ស័យគួរត្រូវបានគេប្រព្រឹត្តចំពោះតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា ភាគីជនជាប់ចោទ ចាប់តាំងពីដំណាក់កាលចាប់ផ្ដើមរហូតដល់ដំណាក់កាលប្ដឹងតវ៉ាចុងក្រោយ។

ក្រមព្រហ្មទណ្ឌ បានចែងអំពីចំណាក់ថ្នាក់បទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍នៃការដាក់ទោស យុត្តាធិការនៃតុលាការជាអាទិ៍។ ជារួមសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ទាមទាឱ្យមានការទទួលស្គាល់ និងការការពារសិទ្ធិ យ៉ាងពិតប្រាកដ ដែលសិទ្ធិទាំងនេះរួមមានសិទ្ធិទទួលបានការសន្មត់ថាគ្មានទោស សិទ្ធិត្រូវបានជំនុំជំរះដោយឥតពន្យារពេលយូរហួសហេតុ និងសិទ្ធិត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងដោះបន្ទុក។



### ២.៣.១ សិទ្ធិទទួលបាននូវសវនាការជាសាធារណៈ

ការជំនុំជម្រះជាសាធារណៈ ធានាថាប្រព័ន្ធយុត្តិធម៌មានតម្លាភាព និងធានាថាអំណាចតុលាការមានទំនួលខុសត្រូវចំពោះសាធារណៈជន នូវរាល់សេចក្តីសម្រេចដែលខ្លួនបានសម្រេច។

សិទ្ធិក្នុងការទទួលបាននូវសវនាការជាសារធារណៈ មានន័យថា គូក្តីនៅក្នុងរឿងក្តី និងសាធារណៈជនទូទៅមានសិទ្ធិ ក្នុងការចូលរួម។ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ។[៤៩] ធាតុសំខាន់ដែលត្រូវមានក្នុងសវនាការជាសាធារណៈ គឺការបើកចំហជាទូទៅសម្រាប់សាធារណជន និងធ្វើឡើងដោយផ្ទាល់មាត់។ សាធារណៈជនត្រូវទទួលបានព័ត៌មានអំពីទីតាំង និងកាលបរិច្ឆេទនៃសវនាការ។ សាធារណៈជនមានសិទ្ធិចូលរួមស្តាប់ ដើម្បីស្វែងយល់ពីរបៀបដែលគេចាត់ចែងការងារយុត្តិធម៌ និងដើម្បីស្វែងយល់ថាតើគេធ្វើសេចក្តីសម្រេចដូចម្តេចខ្លះ ស្របតាមនីតិវិធី ឬមានការជ្រៀតជ្រែកពីឥទ្ធិពលភាគីខាងក្រៅដែរឬយ៉ាងណា?

គ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ។[៥០] បន្ថែមពីនេះទៀតសវនាការជាសាធារណៈចាំបាច់ត្រូវធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ ដើម្បីឱ្យជនជាប់ចោទអាចបានឮ និងឆ្លើយតបចំពោះសំណុំរឿងដែលបានប្តឹងប្រឆាំងរូបខ្លួន ព្រមទាំងបង្ហាញការការពារខ្លួន។

សិទ្ធក្នុងការចូលរួមក្នុ ងសវនាការជាសាធារណៈអាចត្រូវបានកំណត់នៅក្នុងកាលៈទេសៈពិតប្រាកដណាមួយ។ បើតុលាការយល់ឃើញថាសាធារណជនបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ នោះតុលាការអាចបង្គាប់ឱ្យការពិភាក្សា ដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់។[៥១] ឧទាហរណ៍ ករណីបទល្មើសរំលោភសេពសន្ធវៈ ឬជនជាប់ចោទជាអនីតិជន។



---

[៤៩] មាត្រា ៣៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៥០] មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៥១] មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ២.៣.២ ការសន្មត់ជាមុនថាគ្មានទោស

ការសន្មត់ទុកជាមុនថាថាគ្មានទោស គឺជាសិទ្ធិមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកល ថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលសិទ្ធិនេះអនុវត្តនៅពេញនីតិវិធីនៃការស៊ើបអង្កេត និងការជនុំជម្រះផ្នែកព្រហ្មទណ្ឌ រហូតដល់ការបញ្ចប់បណ្ដឹងឧបាស្រ័ចុងក្រោយ។ ជនណាក៏ដោយបានជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវចាត់ទុកថាគ្មានទោស រហូតពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនការជាសាធារណៈ ដែលមានការធានាចាំបាច់ឱ្យជននោះការពារខ្លួន។[៥២] ដូចគ្នាដែរ ចំពោះមាត្រា ៨៤ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំបានចែងថា (១) ជនដែលត្រូវឃាត់ខ្លួន ឬជាប់ឃុំ ពីបទចោទណាមួយ ទោះបីស្ថិតក្នុងកន្លែងឃាត់ខ្លួន របស់នគរបាលយុត្តិធម៌ ឬស្ថិតក្នុងពន្ធនាគារ តែនៅមិនទាន់បានធ្វើការជំរំជម្រះ និងសម្រេចផ្ដន្ទាទោសត្រូវចាត់ទុកថា **ជនជាប់ឃុំមិនទាន់ជំរុះជម្រះ** ។ (២) ជនជាប់ឃុំទាំងឡាយណាដែលពុំទាន់សម្រេចថាមានពិរុទ្ធភាពនៅឡើយ ត្រូវត្រូវសម្មត់ថាជា **ជនគ្មានទោស** ហើយត្រូវទទួលការថែទាំដូចមនុស្សធម្មតា។ ចំពោះមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏បានចែងផងដែរថា **ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ**។ មានន័យថាជនជាប់ចោទម្នាក់ត្រូវបានសន្មត់ទុកជាមុនថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់ និងតុលាការចេញសាលក្រម ឬសាលដីកា ឬសេចក្ដីសម្រេច ចូលជាស្ថាពរ។

ម្យ៉ាងវិញទៀត គោលការណ៍ដែលថា បន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ គឺមានប្រភពមកពីការសន្មត់ទុកមុនថាគ្មានទោស។ មានន័យថា បើទោះបីជាជនជាប់ចោទមិននិយាយអ្វីទាំងអស់ ហើយមិនបង្ហាញភស្តុតាងអ្វីទាល់តែសោះក៏ដោយ ក៏ជនជាប់ចោទត្រូវបានរួចផុតពីបទចោទប្រកាន់ ប្រសិនបើអយ្យការមិនអាចបង្ហាញភស្តុតាងដាក់បន្ទុក ឬអាចនិយាយម្យ៉ាងទៀតថា ជនជាប់ចោទពុំមានកាតព្វកិច្ចត្រូវបង្ហាញភស្តុតាងដើម្បីបង្ហាញថាខ្លួនជាជនគ្មានទោសឡើយ។

លើសពីនេះទៅទៀត ដើម្បីកាន់តែដាក់លាក់ការសន្មត់ជាមុនថាគ្មានទោសតម្រូវឱ្យ ៖

- តុលាការមិនត្រូវធ្វើការសម្រេចសេចក្ដីមុនពេលសវនាការ
- ពិរុទ្ធភាពដែលហួសពីវិមតិសង្ស័យ ចាំបាច់ត្រូវបង្ហាញភស្តុតាងដោយអយ្យការ
- ការប្រព្រឹត្តចំពោះជនជាប់ចោទ មិនត្រូវធ្វើឡើងក្នុងលក្ខណៈដែលបង្ហាញថាជនជាប់ចោទ ជាជនមានពិរុទ្ធភាពដូចគ្នានឹងទណ្ឌិត

[៥២] មាត្រា ១១ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

- ប្រព័ន្ធផ្សព្វផ្សាយគួរជៀសវាងការផ្សាយព័ត៌មានដែលបំផ្លាញដល់ការសន្និត់ទុកជាមុនថាគ្មានទោស
- ជៀសវាងជនជាប់ចោទចូលរួមក្នុងសវនាការក្នុងឯកសណ្ឋានជាទណ្ឌិត[៥៣]

ករណីជនជាប់ចោទបង្ហាញខ្លួនក្នុងឯកសណ្ឋានទណ្ឌិត បានប៉ះពាល់យ៉ាងខ្លាំងចំពោះសិទ្ធសន្និត់ជាមុនថាគ្មានទោសជាខ្លាំង។ ជនជាប់ចោទគ្រប់រូបមានសិទ្ធិត្រូវបាននាំខ្លួនទៅកាន់តុលាការក្នុងរូបភាព និងកិត្តិយសជាជនគ្មានទោស។ នៅពេលដែលជនជាប់ចោទត្រូវបានចូលរួមក្នុងសវនាការ ក្នុងឯកសណ្ឋានជាអ្នកទោស ឬមានជាប់ខ្នោះ ធ្វើឱ្យមានការសន្និត់ថាជនជាប់ចោទមានពិរុទ្ធភាព ឬជាឧក្រិដ្ឋជនដ៏មានគ្រោះថ្នាក់ ឬជនល្មើស ដែលត្រូវបានតុលាការផ្តន្ទាទោសរួចហើយ។ ទាំងអស់នេះអាចជាហេតុដែលធ្វើឱ្យជះឥទ្ធិពលដល់ការវិនិច្ឆ័យនិងលទ្ធផល នៃរឿងក្តី។

### ២.៣.៣ សិទ្ធិទទួលបាននូវការជំនុំជំម្រះដោយគ្មានពន្យាពេល

សម្រាប់ជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ហើយស្ថិតនៅក្នុងការឃុំឃាំង កាតព្វកិច្ចនៃរដ្ឋនោះ ត្រូវនាំយករឿងក្តីនោះមកជំនុំជម្រះសេចក្តីក្នុងពេលវេលាសមស្រប។

សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល ផ្សារភ្ជាប់ទៅនឹងសិទ្ធិមានសេរីភាព។ ជាគោលការណ៍ ជនជាប់ចោទត្រូវនាំខ្លួនទៅកាន់តុលាការអោយបានក្នុងរយៈពេលដ៏ខ្លីបំផុត និងត្រូវជំនុំជម្រះក្នុងរយៈពេលដល់សមស្រប។[៥៤] តាមរយៈគោលការណ៍នេះហើយដែលបង្កើតឱ្យមានសច្ចធារណ៍ ប្រឆាំងនឹងការឃុំខ្លួនជនជាប់ចោទទាំងឡាយណាដែលកំពង់រង់ចាំការជំនុំជម្រះ។ ការឃុំខ្លួនអាចធ្វើឡើងក្នុងករណីចាំបាច់ ដូចជា៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវ រ៉ូវគ្នា រវាងជនជាប់ចោទនិងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[៥៥]

---

[៥៣] ឯកសណ្ឋានទណ្ឌិតសំដៅលើឯកសណ្ឋានពណ៌ខៀវដែលក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសថាជាឯកសណ្ឋានសម្រាប់ទណ្ឌិតដែលមានសាលក្រម ឬសាលដីកាបានចូលជាស្ថាពររួចហើយ។

[៥៤] មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ និងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៥៥] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ បានចែងយ៉ាងច្បាស់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យាពេល។ បន្ថែមពីនេះសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យាពេលក៏មានចែងនៅក្នុងច្បាប់ជាតិ ដោយមាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។ ដូចនេះ ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌណាមួយ មានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យាពេល។ សិទ្ធិនេះមានសារៈសំខាន់ ដោយសារមូលហេតុជាច្រើនដូចជា៖

- សិទ្ធិនេះធានាថាជនជាប់ចោទ ដែលត្រូវបានឃុំខ្លួនក្នុងអំឡុងពេលសវនាការមិនត្រូវបានដកហូតសេរីភាពយូរហួសហេតុ
- សិទ្ធិនេះការពារជនជាប់ចោទពីការបន្តឃុំខ្លួនដោយគ្មានការជំនុំជម្រះ
- សិទ្ធិនេះកាត់បន្ថយភាពអយុត្តិធម៌ ដោយធានាថាបុគ្គលគ្មានកំហុសដែលរងការចោទប្រកាន់ពីបទល្មើស នឹងមិនត្រូវបន្តឃុំខ្លួនដោយសារបទល្មើសដែលខ្លួនមិនបានប្រព្រឹត្ត



### ២.៣.៤ សិទ្ធិត្រូវមានការសួរចម្លើយ និងត្រូវពិនិត្យសាក្សី

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ។ ហេតុដូច្នេះ នេះជាការសំខាន់ដែលផ្តល់ឱកាសសម្រាប់ភាគីនីមួយៗដើម្បីបង្ហាញភស្តុតាង និងហៅសាក្សីនានាដែលគាំទ្រដល់សំណុំរឿងរបស់ខ្លួន។[៥៦] នេះជារឿងសំខាន់ដូចគ្នាដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីសួរដេញដោលសាក្សី និងបដិសេធរាល់ភស្តុតាងដែលខ្លួនមិនទទួលយក។

ធាតុផ្សំជាមូលដ្ឋាន នៃគោលការណ៍ស្មើភាពគ្នារវាងភាគី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញនូវការការពារខ្លួន គឺជាសិទ្ធិរបស់ជនជាប់ចោទក្នុងការសុំសួរចម្លើយសាក្សី។[៥៧] សិទ្ធិក្នុងការសុំឱ្យសួរចម្លើយសាក្សីធានាថាមេធាវីមានឱកាសក្នុងការចោទសួរសាក្សីដែលនិងផ្តល់ភស្តុតាង តាងនាមឱ្យជនជាប់ចោទដើម្បីតទល់នឹងភស្តុតាងប្រឆាំងនឹងជនជាប់ចោទ។ ជនជាប់ចោទ មានសិទ្ធហៅសាក្សីរបស់ខ្លួន និងសាកសួរដូចនេះជនជាប់ចោទត្រូវមានឱកាស និងពេលវេលាគ្រប់គ្រាន់ ដើម្បីសាកសួរសាក្សីរបស់ខ្លួន សាក្សីភាគីបដិបក្ខ និងភស្តុតាងទាំងអស់ដែលបង្ហាញក្នុងសវនាការ។ ម្យ៉ាងវិញទៀត ជនជាប់ចោទអាចបង្ហាញសាក្សីណាមួយ ដែលពុំទាន់បានកោះហៅដោយព្រះរាជអាជ្ញា និងស្នើឱ្យតុលាការស្តាប់ចម្លើយរបស់ពួកគេក្នុងឋានៈជាសាក្សី។

ការសាកសួរសាក្សីដោយអង្គអយ្យការ និងមេធាវី ដែលផ្តល់ឱ្យតុលាការនូវឱកាសដើម្បីសង្កេតមើលភស្តុតាង និងស្តាប់អំពីការដេញដោលផ្អែកច្បាប់ទាក់ទិននឹងភស្តុតាង។ ការណ៍នេះជួយឱ្យតុលាការ ធ្វើការវាយតម្លៃលើអំណះអំណាងផ្សេងៗដែលបានបង្ហាញ និងធ្វើសេចក្តីសម្រេច។



[៥៦] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៥៧] មាត្រា ១៤ (៣.ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

# ជំពូកទី៣

# ការបន្ធូរបន្ថយទោស និងការលើកលែងទោស

# ជំពូកទី៣

# ការបន្ធូរបន្ថយទោស និងការលើកលែងទោស

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ព្រះរាជសិទ្ធិឱ្យព្រះមហាក្សត្រ ឡាយព្រះហស្តលេខាដើម្បីបន្ធូរបន្ថយទោស ឬលើកលែងទោសទាំងស្រុង។[៥៨] បានន័យថាការបន្ធូរបន្ថយទោស ឬការលើកលែងទោស គឺជាព្រះរាជសិទ្ធិផ្តាច់មុខរបស់អង្គព្រះមហាក្សត្រ។[៥៩] ការបន្ធូរបន្ថយទោស និងការលើកលែងទោសមិនអាចធ្វើឡើងតាមការនឹកឃើញនោះឡើយ គឺមានការកំណត់លក្ខខណ្ឌ នីតិវិធី យ៉ាងច្បាស់ក្នុងក្រឹត្យលេខ ២៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៧២និងមាត្រា៣៨២ ព្រមជាមួយច្បាប់ស្តីពីពន្ធនាគារ ។

## ៣.១ លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស

ការបន្ធូរបន្ថយទោស គឺជាការបន្ថយចិរវេលានៃការទទួលទោសរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ ។ ការបន្ធូរបន្ថយទោសអាចធ្វើទៅបាន លុះត្រាតែទណ្ឌិតបានបំពេញនូវលក្ខខណ្ឌដូចតទៅ[៦០]៖

- ទណ្ឌិតបានភ្ញាក់រលឹក កែប្រែខ្លួនបានល្អប្រសើរ និងបានប្តេជ្ញាចិត្ត ខិតខំអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋល្អ សុចរិក ដែលមានប្រយោជន៍សម្រាប់សង្គមជាតិ។
- ទណ្ឌិតក៏បានយកចិត្តទុកដាក់ ក្នុងការបំពេញការងារពលកម្មយ៉ាងសកម្មនិងទៀងទាត់ ជាពិសេសអាចជាគំរូដ៏ល្អចំពោះទណ្ឌិតដ៏ទៃ។
- ទណ្ឌិតគោរព ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនតាមបទបញ្ជាផ្ទៃក្នុងនិងវិន័យផ្សេងៗក្នុងពន្ធនាគារ។
- ទណ្ឌិតដែលបានទទួលរងទោស ឬអនុវត្តទោសបានមួយភាគបី (១/៣) នៃទោសរបស់ខ្លួន ឬបានទទួលរងទោសបាន ៧ ឆ្នាំ នៃទោសមួយជីវិតដែលតុលាការបានសម្រេចក្នុងសាលក្រម ឬសាលដីកា។
- ម្យ៉ាងវិញទៀត ទណ្ឌិតផ្ទាល់ក៏ត្រូវធ្វើការស្នើសុំបន្ធូរបន្ថយទោសរបស់ខ្លួនតាមរយៈប្រធានពន្ធនាគារ។

ការបន្ធូរបន្ថយមិនអាចប្រព្រឹត្តទៅបាន បើគ្មានការចូលរួមពីមន្ត្រីមានសមត្ថកិច្ច ក្នុងនោះមានប្រធានពន្ធនាគារដែលជាអ្នកដើរតួនាទីសំខាន់នៅក្នុងនីតិវិធីមួយនេះ។ តួនាទីរបស់ប្រធានពន្ធនាគាររួមមាន[៦១]៖

[៥៨] មាត្រា ២៧ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[៥៩] តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី

[៦០] នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង

[៦១] នីតិវិធីលេខ២២៧ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស រៀបរៀងដោយក្រសួងមហាផ្ទៃ ឆ្នាំ២០០៣

- ប្រធានពន្ធនាគារត្រូវផ្ញើបញ្ជូនបញ្ជីឈ្មោះទណ្ឌិតដែលបានស្នើសុំសម្រាប់ការបន្ធូរបន្ថយទោស ឱ្យបាន ៤២ ថ្ងៃមុនពេល បុណ្យវិសាខបូជា បុណ្យចូលឆ្នាំខ្មែរ និងបុណ្យអុំទូក។
- ប្រធានពន្ធនាគារ ត្រូវផ្ញើភ្ជាប់ជាមួយពាក្យសុំបន្ធូរបន្ថយទោសនូវរបាយការណ៍បូកសរុប អំពីអាកប្បកិរិយារបស់ទណ្ឌិត ការងារដែលបានធ្វើនៅក្នុងពន្ធនាគារ និងកម្រិតសន្តិសុខរបស់ទណ្ឌិត។
- ប្រធានមណ្ឌលអប់រំកែប្រែត្រូវបញ្ជូនបញ្ជីឈ្មោះសុំការបន្ធូរបន្ថយទោសទណ្ឌិត ទៅឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ហើយរក្សាទុកមួយច្បាប់នៅក្នុងមណ្ឌលអប់រំកែប្រែ។ ចំពោះពន្ធនាគារខេត្ត-ក្រុង ប្រធានពន្ធនាគារត្រូវបញ្ជូនបញ្ជីឈ្មោះសុំបន្ធូរបន្ថយទោសទណ្ឌិត ទៅតុលាការសាមីខេត្ត-ក្រុង ដោយចម្លងមួយច្បាប់ទៅឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ហើយរក្សាទុកមួយច្បាប់នៅក្នុងពន្ធនាគារ។
- ចំនួននៃការ បន្ធូរបន្ថយទោសចំពោះទណ្ឌិត ដែលមានសិទ្ធិទទួលបានការបន្ធូរបន្ថយទោសមានដូចតទៅ៖
  - ទណ្ឌិតដែលទទួលរងទោស ឬអនុវត្តទោសក្នុងចន្លោះរវាងពី ១ ឆ្នាំ និង ១០ ឆ្នាំ អាចត្រូវបានបន្ធូរបន្ថយទោសចំនួន ៦ខែ។
  - ទណ្ឌិតដែលទទួលរងទោស ឬអនុវត្តទោសក្នុងចន្លោះរវាងពី ១០ ឆ្នាំ និង ១៥ ឆ្នាំ អាចត្រូវបានបន្ធូរបន្ថយទោសចំនួន ៩ខែ។
  - ទណ្ឌិតដែលទទួលរងទោស ឬអនុវត្តទោសក្នុងចន្លោះរវាងពី ១៥ ឆ្នាំ និង ២០ ឆ្នាំ អាចត្រូវបានបន្ធូរបន្ថយទោសចំនួន ១២ ខែ។
  - ទោសមួយជីវិត អាចត្រូវបានបន្ធូរបន្ថយលើកដំបូងមកត្រឹម ២០ឆ្នាំ ហើយទណ្ឌិតប្រភេទនេះអាចនឹងមានសិទ្ធិទទួលបានការបន្ធូរបន្ថយទោសបន្ថែមទៀត។

## ៣.២ លក្ខខណ្ឌនៃការលើកលែងទោស

ការលើកលែងទោស គឺជាការដោះលែងទណ្ឌិតឱ្យមានសេរីភាពឡើងវិញ មុនការកំណត់ក្នុងសាលក្រម សាលដីកា ឬសេចក្តីសម្រេចរបស់តុលាការ។

ការលើកលែងទោសអាចធ្វើទៅបាន លុះត្រាតែទណ្ឌិតបានគោរព និងបំពេញនូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ទណ្ឌិតបានភ្ញាក់រលឹក កែប្រែខ្លួនបានល្អប្រសើរ និងបានប្ដេជ្ញាចិត្ត ខិតខំអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋល្អ សុចរិត ដែលមានប្រយោជន៍សម្រាប់សង្គមជាតិ។
- ទណ្ឌិតក៏បាន យកចិត្តទុកដាក់ក្នុងការបំពេញការងារពលកម្មយ៉ាងសកម្ម និងទៀងទាត់ ជាពិសេសអាចជាគំរូដ៏ល្អចំពោះទណ្ឌិតដ៏ទៃ។
- ទណ្ឌិតគោរព ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនតាមបទបញ្ជាផ្ទៃក្នុងនិងវិន័យផ្សេងៗក្នុងពន្ធនាគារ។
- ទណ្ឌិតត្រូវទទួលរងទោស ឬអនុវត្តទោសចំនួន ២/៣ (ពីរភាគបី) នៃទោសដែលតុលាការបានសម្រេចក្នុងសាលក្រម ឬសាលដីកា។
- ម្យ៉ាងវិញទៀត ទណ្ឌិតផ្ទាល់ក៏ត្រូវធ្វើការស្នើសុំលើកលែងទោសរបស់ខ្លួនតាមរយៈប្រធានពន្ធនាគារ។

ក្រៅពីទណ្ឌិតបានអនុវត្តនូវលក្ខខណ្ឌដូចបានរៀបរាប់ខាងលើហើយ មន្ត្រីមានសមត្ថកិច្ចពាក់ពន្ធ ពោលគឺប្រធានពន្ធនាគារ ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការ នៃនីតិវិធីការលើកលែងទោសនេះ។ ប្រធានពន្ធនាគារ ត្រូវបំពេញភារកិច្ចដូចជា[៦២]៖

- ប្រធានពន្ធនាគារត្រូវ ផ្ញើបញ្ជូនបញ្ជីឈ្មោះទណ្ឌិតដែលបានស្នើសុំសម្រាប់បន្ធូរបន្ថយ ឬលើកលែងទោសឱ្យបាន៤២ថ្ងៃ មុនពេល បុណ្យវិសាខបូជា បុណ្យចូលឆ្នាំខ្មែរ និងបុណ្យអុំទូក។
- ប្រធានពន្ធនាគារត្រូវធានាថា ពាក្យស្នើសុំលើកលែងទោសត្រូវផ្ញើភ្ជាប់ជាមួយរបាយការណ៍បូកសរុបអំពីអាកប្បកិរិយារបស់ទណ្ឌិត ការងារដែលបានធ្វើនៅក្នុងពន្ធនាគារ និងកម្រិតសន្តិសុខរបស់ទណ្ឌិត។
- ប្រធានពន្ធនាគារត្រូវធានាថា រាល់ទណ្ឌិតទាំងអស់ដែលត្រូវបានស្នើសុំលើកលែងទោស ត្រូវទទួលរងទោសបានពីរភាគបីនៃទោសរបស់ខ្លួន ឬទទួលរងទោសបាន ១៥ឆ្នាំ នៃទោសមួយជីវិត។
- ការលើកលែងទោសដោយគ្មានកម្រិតពេលវេលា ដែលអាចត្រូវបានសណ្ដោសប្រណីដោយព្រះមហាក្សត្រចំពោះទណ្ឌិតដែល មានជម្ងឺមិនអាចព្យាបាលបាន មានជម្ងឺធ្ងន់ធ្ងរ ឬវ័យចាស់ជរាដែលអាចបណ្ដាល ឱ្យស្លាប់បើសិនជានៅតែឃុំខ្លួនក្នុងពន្ធនាគារ។ ក្នុងករណីនេះ ពាក្យសុំលើកលែងទោសត្រូវភ្ជាប់ជាមួយនូវរបាយការណ៍របស់មន្ត្រីពេទ្យ។
- ប្រធានមណ្ឌលអប់រំកែប្រែត្រូវបញ្ជូនបញ្ជីឈ្មោះសុំការលើកលែងទោសទណ្ឌិត ទៅឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ហើយរក្សាទុកមួយច្បាប់នៅក្នុងមណ្ឌលអប់រំកែប្រែ។ ចំពោះពន្ធនាគារ

[៦២] នីតិវិធីលេខ២៧ ស្ដីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស រៀបរៀងដោយក្រសួងមហាផ្ទៃ ឆ្នាំ២០០៣

ខេត្ត-ក្រុង ប្រធានពន្ធនាគារត្រូវបញ្ជូនបញ្ជីឈ្មោះសុំលើកលែងទោសទណ្ឌិតទៅតុលាការសាមី ខេត្ត-ក្រុង ដោយចម្លងមួយច្បាប់ទៅឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ហើយរក្សាទុកមួយច្បាប់ នៅក្នុងពន្ធនាគារ។





## ៣.៣ អានុភាពនៃការលើកលែងទោស

ការលើកលែងទោស មានអានុភាពរំលត់បណ្តឹងអាជ្ញា។ ទណ្ឌិតត្រូវបានលើកលែងទោសពីបទល្មើស នឹងមិនអាចមាននរណាចោទប្រកាន់ ឬដាក់ទោសលើបទល្មើសនោះទៀតឡើយ។ ទណ្ឌិតមានសិទ្ធិសេរីភាពបានតាមច្បាប់កំណត់។

នៅពេលដែលទណ្ឌិតត្រូវបាន លើកលែងទោសប្រធានពន្ធនាគារត្រូវដោះលែងទណ្ឌិតនោះជាបន្ទាន់។

ចំពោះទណ្ឌិត ដែលត្រូវបានឃុំឃាំងក្នុងពន្ធនាគារថ្នាក់ជាតិ នៅពេលទទួលបានដីកាដោះលែងពីតុលាការ ត្រូវបញ្ជូនទៅប្រធាននាយកដ្ឋានពន្ធនាគារដើម្បីធ្វើការរៀបចំជាលិខិតដោះលែងដែលត្រូវបានចុះហត្ថ-លេខាដោយប្រធាននាយកដ្ឋានពន្ធនាគារ។

ចំពោះទណ្ឌិត ដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារខេត្ត-ក្រុង នៅពេលទទួលបាន ដីកាដោះលែងពីតុលាការ ត្រូវបញ្ជូនទៅប្រធានពន្ធនាគារ។ ប្រធានពន្ធនាគារ ត្រូវផ្តល់លិខិតដោះលែងមួយច្បាប់ទៅឱ្យទណ្ឌិតដែលត្រូវបានដោះលែង ហើយរក្សាទុកលិខិតដោះលែងមួយច្បាប់ក្នុងពន្ធនាគារ។

មន្ត្រីពន្ធនាគារទទួលបន្ទុកក្នុងការដោះលែងទណ្ឌិត ត្រូវ

- ឱ្យទណ្ឌិតប្រគល់ទ្រព្យសម្បត្តិពន្ធនាគារមកវិញ និងរាប់ចំនួន
- ឆែកឆេរទណ្ឌិត
- សរសេរកំណត់ចំណាំនៅលើសំណុំឯកសារផ្ទាល់ខ្លួនរបស់ទណ្ឌិតថា «ត្រូវបានដោះលែង» និងកាលបរិច្ឆេទនៃការដោះលែង។
- ដកឈ្មោះទណ្ឌិតចេញពីសៀវភៅបញ្ជីរាប់ចំនួននៅក្នុងបន្ទប់ឃុំឃាំង។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេល ដ៏យូរកន្លងមកនេះទៅ លើប្រធានបទស្តីពី **សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ** បានធ្វើឱ្យយើងខ្ញុំទទួលបានការស្វែងយល់យ៉ាងច្រើន អំពីអត្ថប្រយោជន៍នៃសិទ្ធិរបស់ជនល្មើស ពីព្រោះបុគ្គលនេះជាដើមហេតុយ៉ាងសំខាន់ ដែលធ្វើឲ្យលេចចេញនូវរឿងក្តីព្រហ្មទណ្ឌ ឬក៏អាចនិយាយម្យ៉ាងទៀតបានថាជាបុគ្គល ដែលបានធ្វើអោយរឿងក្តីព្រហ្មទណ្ឌដំណើរការ។ ជាងនេះទៅទៀតជនល្មើស ភាគច្រើនតែងតែជាពលរដ្ឋសាមញ្ញដែលពេលខ្លះ អាចយល់ដឹងមិនអស់អំពីច្បាប់ ឬសិទ្ធិដែលខ្លួនមាន ជាពិសេស គឺសិទ្ធិនៅក្នុងដំណាក់កាលជាជនល្មើសនេះឯង ហេតុនេះហើយទើបទាមទារ ឱ្យមានអ្នកប្រឹក្សា ឬក៏អ្នកជំនួយផ្នែកច្បាប់ (មេធាវី ឬបុគ្គលផ្សេងទៀតដែលយល់ដឹងអំពីច្បាប់ច្បាស់លាស់) ជួយពន្យល់ និងផ្តល់យោបល់បន្ថែមដើម្បីខ្លួនរួចផុតពី ការសួរចម្លើយដោយគ្មានអំពើហិង្សា ទារុណកម្ម ឬក៏ពន្យល់ឱ្យយល់ដឹងអំពីសិទ្ធិដែលខ្លួនគួរទទួលបានក្នុងពេលឃាត់ខ្លួនបានយ៉ាងច្បាស់ ដូចជា សិទ្ធិទទួលបានគ្រូពេទ្យ អ្នកបកប្រែ មេធាវីជាអាទិ៍ និងការទទួលបានការជំនុំជម្រះឱ្យយុត្តិធម៌ មិនលំអៀង អញ្ញាក្រឹត្យ នៅចំពោះមុខតុលាការ។

យោងតាមការបកស្រាយប្រធានខាងលើ យើងឃើញថានៅក្នុងរឿងក្តីព្រហ្មទណ្ឌ មានពាក្យហៅជនល្មើសជាច្រើនខុសៗគ្នា តាំងពីនៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ ការជំនុំជម្រះនៅចំពោះមុខតុលាការ ពាក្យទាំងនោះមានដូចជា ជនសង្ស័យជនល្មើសជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន និង ទណ្ឌិត។ ប៉ុន្តែទោះបីជាយ៉ាងណា តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជា ច្បាប់ស្តីពីពន្ធនាគារ ដែលបានផ្តល់សម្បទានូវសិទ្ធិការពារ ជាច្រើន ចាប់តាំងពីដំណាក់កាលឃាត់ខ្លួនដំបូងរហូតដល់មានដំណាក់កាលការឃុំខ្លួន បណ្តោះអាសន្ន ពីព្រោះគាត់ គឺជាជនដែលត្រូវបានកាត់ផ្តាច់សិទ្ធិសេរីភាពមួយចំនួននៅពេលដែលគាត់ខ្លាចជាជនល្មើស។ ទាំងច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ សឹតសឹងតែបានបញ្ញត្តការពារជនត្រូវចោទដូចគ្នា។ នេះបើតាមការជាក់ស្តែងការបញ្ញត្តពាក់ព័ន្ធនឹងគោលលការណ៍សច្ចធារណ៍នៃនិរទោស ឬគោលការណ៍ សន្មតទុកជាមុនថាគ្មានទេស កាលណាមិនទាន់មានសាលក្រម ឬសាលដីកាស្ថាពរទេ ដែលគោលការណ៍នេះក៏ មានចែងនៅក្នុងមាត្រា ៣៨ កថា-ខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ផងដែរ។

សរុបសេចក្តីមក ថ្វីត្បិតតែច្បាប់បានបញ្ញតិផ្តល់ឱ្យនូវសិទ្ធិជាច្រើនដល់ ជនល្មើសនៃរឿងក្តីព្រហ្មទណ្ឌ ក៏ពិតមែន ប៉ុន្តែក្នុងគោលបំណងធានាឱ្យបាននូវលំហូរនៃនីតិវិធីនីមួយៗប្រព្រឹត្តិទៅដោយរលូន និងមិនមានករណីបំពាន **សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ** ណាមួយត្រូវបានកើតឡើងទេក្នុងពេលកំពុងដំណើរការ

រឿងក្តី។ តែទន្ទឹមនឹងនេះផងដែរយើងឃើញថា បច្ចុប្បន្នការអនុវត្តនូវ **សិទ្ធិរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ** ទាំងនេះហាក់នៅមានភាពទន់ខ្សោយ ពីព្រោះគេនៅតែសង្កេតឃើញមានការធ្វើទារុណកម្ម ឬក៏អំពើហឹង្សាលើជនល្មើសនៅឡើយទេ។ ដូចនេះជនល្មើសគួរតែរកមេធាវីភ្លាមៗនៅពេលដែលមានការឃាត់ខ្លួនកើតឡើង ដើម្បីធានាអំពីសិទ្ធិរបស់ខ្លួន ដែលមិនត្រូវបានអ្នកដ៏ទៃបំពាន តែការមិនបំពាននេះក៏ទាមទារឱ្យ មានការចូលរួមពីសំណាក់មន្ត្រីពាក់ព័ន្ធ នៅក្នុងនីតិវិធីអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ផងដែរ។ ជាការពិតណាស់ ប្រសិនបើការគោរពសិទ្ធិមនុស្សប្រព្រឹត្តទៅបានល្អប្រសើរ គួបផ្សំជាមួយនឹងការមិនប្រព្រឹត្តនូវអំពើពុករលួយទៀតនោះ ប្រទេសកម្ពុជានឹងក្លាយជាប្រទេសដែលមាននីតិរដ្ឋពេញលេញ ហើយប្រជាពលរដ្ឋប្រាកដជារស់នៅប្រកបដោយសុខសន្តិភាព។

# អនុសាសន៍

# អនុសាសន៍

ដើម្បីចូលរួមចំណែកធ្វើឱ្យសារណារបស់យើងខ្ញុំ កាន់តែល្អ និងរឹតតែមានប្រសិទ្ធភាពខ្ពស់ឡើង ហើយអាចយកទៅអនុវត្តន៍បាន យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

- ❖ ពង្រឹងវិស័យអប់រំ ក្នុងគោលដៅធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែខ្ពស់ ហើយខ្លាចរអាចំពោះការប្រព្រឹត្តអំពើបំពានច្បាប់ ដើម្បីកាត់បន្ថយបទល្មើសនានាដែលអាចកើតឡើងជាយថាហេតុ ហើយនឹងគ្មានការប្រព្រឹត្តិបទល្មើសកើតឡើងទៀតផង។
- ❖ ជនល្មើស ឬជនជាប់ចោទគួរតែសហការគ្នា ជាមួយមន្ត្រីមានសមត្ថកិច្ចពាក់ពន្ធដើម្បីសម្រួលដល់ការស៊ើបអង្កេតកាន់តែមានភាពងាយស្រួល។
- ❖ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែលុបបំបាត់ចោលនូវអំពើពុករលួយ ជាពិសេសអ្នកធ្វើកំណត់ហេតុអ្នកធ្វើកោសលវិច័យ ដើម្បីជម្រុញឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងតម្លាភាព។
- ❖ ធ្វើការផ្សាយច្បាប់ឱ្យកាន់តែទូលំទូលាយអំពីសិទ្ធិរបស់ជនល្មើស ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីពន្ធនាគារ ក៏ដូចជាច្បាប់ផ្សេងទៀត ទាំងច្បាប់ជាតិ និងអន្តរជាតិ ដល់អាជ្ញាធរមានសមត្ថកិច្ច ក៏ដូចជាប្រជាពលរដ្ឋដើម្បីបានជ្រួតជ្រាប និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធិភាព និងគ្មានការបំពាន់ផ្សេងៗត្រូវបានកើតឡើង។
- ❖ ជម្រុញការចូលរួមសរសេរសៀវភៅដែលពាក់ព័ន្ធនឹងច្បាប់ ពីសំណាក់សាស្ត្រាចារ្យផ្នែកនីតិសាស្ត្រក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ទាំងឡាយ ដោយធ្វើការពន្យល់ឱ្យមានភាពងាយយល់ដល់ប្រជាពលរដ្ឋក្នុងគោលបំណងលើកតម្កើនការយល់ដឹងផ្នែកច្បាប់ និងកាត់បន្ថយបទល្មើសនានា។
- ❖ ប្រជាពលរដ្ឋ មិនត្រូវយកអំណាចទឹកប្រាក់ ទៅសូកប៉ាន់ដល់អាជ្ញាធរមានសមត្ថកិច្ចនានា ដើម្បីជាមធ្យោបាយគេចខ្លួនពីការទទួលខុសត្រូវព្រហ្មទណ្ឌ ព្រោះទង្វើទាំងអស់នេះបានជម្រុញឱ្យបទល្មើសកើតមានកាន់តែច្រើនឡើងៗ ហើយបង្កឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។
- ❖ ស្ថាប័នតុលាការត្រូវតែចៀសឱ្យផុតពីការប្រព្រឹត្តនូវអំពើពុករលួយ ដើម្បីកសាងនីតិរដ្ឋឱ្យមានប្រសិទ្ធភាពតទៅមុខទៀត ក៏ដូចជាកាត់បន្ថយភាពអយុត្តិធម៌ដល់ប្រជាពលរដ្ឋស្លូតត្រង់។
- ❖ រាជរដ្ឋាភិបាល គួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ ដល់មន្ត្រីដែលស្ថិតនៅថ្នាក់ក្រោមជាតិ ដោយផ្តោតសំខាន់ទៅលើប្រាក់បៀវត្ស ដើម្បីធ្វើយ៉ាងឱ្យមន្ត្រីទាំងនោះបានបំពេញការងារ ប្រកបដោយការទទួលខុសត្រូវ និងមានមនសិការវិជ្ជាជីវៈខ្ពស់។

# ឯកសារយោង

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តិជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
២. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥
៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
៥. ច្បាប់ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១
៦. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## II. លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨
២. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

## III. សៀវភៅ

១. យុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគាតាមគោលការណ៍សិទ្ធិមនុស្ស របស់លោក Andrew Coyle បោះពុម្ពលើកទី២ ឆ្នាំ២០០៩
២. សៀវភៅនីតិវិធិព្រហ្មទណ្ឌសម្រាប់នគរបាល អំណោយស្ថានទូតបារាំង ឆ្នាំ២០០៩
៣. រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,នីតិវិធីព្រហ្មទណ្ឌ,២០១៣- ២០១៤
៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា រៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១៧

# ឧបសម្ព័ន្ធ